# សៀវភៅ អាល់អ៊ៀកទីកាហ្វ

# الإعتكاف ( فضائل وأحكام)

# អារម្ភកថា

សាសនិកឥស្លាមទាំងអស់ជាទីស្រលាញ់!សាសនាឥស្លាមជាសាសនាតែមួយគត់ដែលអល់ឡោះហ៊ូសុបះាណាហ៊ូវ៉ាតាអាឡើទទួលស្គាល់ និងតបស្នងចំពោះរាល់ទង្វើដែលមនុស្សលោកបានធ្វើស្របតាមបញ្ជារបស់ទ្រង់ ។

ការបួសនៅខែរ៉ម៉ាដន ជាកាតព្វកិច្ចមួយដ៏សំខាន់បំផុតដែលសាសនិកឥស្លាមទាំងអស់ត្រូវបំពេញអោយខាងតែបាន ។ទន្ទឹមនឹងការបំពេញកាតព្វកិច្ចនេះ យើងក៏ត្រូវតែដឹងអំពីច្បាប់ និងប្រការផ្សេងៗដែលធ្វើអោយបួសរបស់យើងទទួលបានជោគជ័យនិងត្រូវបានអល់ឡោះទទួលយក ។ ជាមួយនេះដែរ ចាំបាច់ក៏យើងត្រូវតែដឹងអំពីប្រការមួយចំនួនដែលនាំអោយបួសរបស់យើងត្រូវខូចឬបាត់បង់ ដែលនាំអោយខាតផលបុណ្យឬទទួលបាបកម្ម ។ នៅក្នុងខែបួសនេះដែរ មានប្រការមួយដ៏សំខាន់ដែលត្រូវតែធ្វើដែរនោះគឺការអ៊ិកទីកាហ្វ ។ អ៊ិកទីកាហ្វ ជាធម្មតា គេធ្វើនៅដប់យប់ចុងក្រោយក្នុងខែរ៉ម៉ាដន ។ ការរក្សាខ្លួនអោយបានជាប្រចាំនៅក្នុងម៉ាស្ជិតណាមួយក្នុងអំឡុងពេលនេះដើម្បីធ្វើអំពើល្អផ្សេងៗស្របតាមការបញ្ជារបស់អល់ឡោះនិងរ៉សូលជាការប្រពៃ និងទទួលបាននូវការតបស្នងពីអល់ឡោះ ។

នៅក្នុងសៀវភៅដែលលោកអ្នកកំពុងកាន់នៅដៃនេះ នឹងបង្ហាញអំពីច្បាប់ឥស្លាមខ្លះៗដែលពាក់ព័ន្ធនឹងខែរ៉ម៉ាដន មានបួស និងអ៊ិកទីកាហ្វ ដែលលោកអ្នកអាចសិក្សាស្វែងយល់អោយបានច្បាស់លាស់ និង ជាជំនួយស្មារតីក្នុងការអនុវត្តរបស់យើងអោយបានត្រឹមត្រូវផងដែរ ។ សង្ឃឹមថាលោកអ្នកនឹងបានទទួលជោគជ័យក្នុងការប្រតិបត្តិសាសនាអល់ឡោះ ។

## ការកាន់អំណត់បួស

និយមន័យបួសជាលក្ខណៈភាសា: ការតមចំណីអាហារ ។

និយមន័យបួសជាលក្ខណៈច្បាប់: ការតមចំណីអាហារនិងការរួមភេទចាប់ពីហ្វើជើរ (សេតរុណ) រហូតដល់ថ្ងៃលិច ។

អ្នកកាន់អំណត់បួសជាទីស្រលាញ់! ពួកយើងត្រូវដាក់ខ្លួនដាក់កាយស្វាគមន៍ខែរ៉ម៉ាជនក្នុងនាមជាអ្នកបួងសួងសុំពីអល់ឡោះអោយខែនេះពោរពេញទៅដោយកុសលល្អនិងការរីកចំរើនដល់អ្នកកាន់សាសនាឥស្លាមទូទៅ និងសូមអល់ឡោះទទួលយកកុសលល្អរបស់ពួកយើងនៅក្នុងខែនេះផង ។

ការកាន់អំណត់បួសមួយនឹងមិនត្រឹមត្រូវទេ លុះត្រាតែមាននៀត (ការតាំងចិត្ត) ។

**នៀត**ជាប្រការចាំបាច់ហើយកន្លែងរបស់វានៅក្នុងចិត្តនិងគេតំរូវអោយនៀតរៀងរាល់ថ្ងៃ បើយោងទៅលើទស្សនៈរបស់សាសនវិទូឥស្លាមភាគច្រើន ។

**ផលរបស់អ្នកបួស:**

លោកអាហ្ពូហ៊ូរ៉យរ៉ោះបាននិយាយថា: រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា: (បួសគឺជារនាំងមួយ ដូចនេះអ្នកបួសមិនត្រូវព្យាយាមធ្វើអំពើអកុសល និងមិនត្រូវធ្វើអំពើល្ងង់ខ្លៅណាមួយឡើយ។បើមានជនណាមានបំណងលើជីវិតអ្នកបួសឬជេរប្រទេចអ្នកបួស អ្នកបួសគួរឆ្លើយតបប្រាប់ថា ខ្ញុំកំពុងតែបួស។ ខ្ញុំ(មូហាំម៉ាត់)សូមស្បថនឹងអល់ឡោះថា:ក្លិនម៉ាត់អ្នកបួសក្រអូបជាងក្លិន



គ្រឿងប្រអូបចំពោះអល់ឡោះម្ចាស់ ព្រោះគេបានលះបង់ចំណីអាហារគ្រឿងផឹកនិងចំណង់របស់គេដើម្បីយើង(អល់ឡោះ)គេបួសដើម្បីយើង ដូចនេះយើងជាអ្នកផ្តល់ផលបុណ្យដល់គេដោយការអត់ធ្មត់បួសនេះ ហើយរាល់កុសលល្អមួយនឹងកើនទ្វេរឡើងជាដប់) ។*រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហ្គូខរី*

**បុព្វហេតុដែលច្បាប់ឥស្លាមអនុញ្ញាតអាចស្រាយបួស:**

ពេលឈឺ ពេលធ្វើដំណើរ និងពេលធ្វើការតស៊ូក្នុងបុព្វហេតុរបស់អល់ឡោះ ។

-លោកអាណាសបាននិយាយថា:ពួកយើងបានធ្វើដំណើរជាមួយរ៉ស៊ូលុលឡោះក្នុងខែរ៉ម៉ាជន។ ពួកយើងយល់ឃើញថា បើបុគ្គលណាគេមានកំលាំងគេបួសវាល្អ ហើយបើជនណាទន់ខ្សោយកំលាំង គេស្រាយវាល្អ ។

*(រាយការណ៍ដោយអ៊ីម៉ាំហាហ្ទីស្សទាំងបួន )*

- លោកសើហាល់បាននិយាយថា: ណាហ្ពីបានមានប្រសាសន៍ថា:ពិតណាស់នៅក្នុងឋានសួគ៌មានទ្វារមួយមានឈ្មោះថារ៉យយ៉ើន។ ទ្វារនេះសំរាប់អ្នកបួសចូលនៅថ្ងៃបរលោក គឺគ្មានជនណាអាចចូលក្រៅពីអ្នកបួសឡើយ ។ គេអំពាវនាវរកអ្នកបួសថា: ឯទៅអ្នកបួស? មនុស្សម្នាបានក្រោកឈរឡើងតែគ្មានជនណាបាន ចូលក្រៅពីអ្នកបួសឡើយ លុះពេលពួកគេចូលផុតទ្វារក៏បិត គឺគ្មានជនណាម្នាក់បានចូលតាមទ្វារនោះឡើយ ។

*រាយការណ៍ហាហ្ទីស្សនេះដោយអ៊ីម៉ាំហ្គូខរី*

● អល់ឡោះមានបន្ទូលថាៈ( អល់ឡោះមិនដាក់ទំងន់លើបុគ្គលណាម្នាក់អោយលើសពីលទ្ធភាពរបស់គេឡើយ) ។ (ជំពូកហ្ពឹកក៏រ៉ោះ២៨៦)

● អល់ឡោះមានបន្ទូលបញ្ជាក់ថាៈ( ខែរ៉ម៉ាដនដែលអល់ឡោះបញ្ចុះអាល់គួរអាននៅក្នុងខែនោះ សំរាប់ការចង្អុលបង្ហាញដល់មនុស្សលោក និងបញ្ជាក់នូវការចង្អុលបង្ហាញនិងការបែងចែកខុសនិងត្រូវ ។ បុគ្គលណាដែលទាន់ខែរ៉ម៉ាដនក្នុងចំណោមពួកអ្នក គេត្រូវតែបួស ហើយបុគ្គលណាឈឺ ឬជាអ្នកធ្វើដំណើរ ចូរអោយគេបំពេញវិញតាមចំនួនថ្ងៃដែលគេបានស្រាយនៅថ្ងៃផ្សេង( ក្រៅខែរ៉ម៉ាដន) អល់ឡោះចង់អោយពួកអ្នកបានស្រួល ទ្រង់មិនចង់អោយពួកអ្នកលំបាកឡើយ ហើយពួកអ្នកត្រូវបំពេញតាមចំនួនថ្ងៃស្រាយនោះឡើងវិញ ហើយចូរពួកអ្នកសូត្រធមិបន្ទំអល់ឡោះម្ចាស់តាមអ្វីដែលទ្រង់ចង្អុលបង្ហាញដល់ពួកអ្នក សង្ឃឹមថាពួកអ្នកចេះសំដែងការដឹងគុណ) ។
(ជំពូកហ្ពឹកក៏រ៉ោះ១៨៥)

- ក្មេងដែលមិនទាន់គ្រប់អាយុច្បាប់មិនដាក់កាតព្វកិច្ចបួសលើពួកគេឡើយ ។

- ស្ត្រីមានឈាមរដូវ ឬស្ត្រីមានឈាមបន្ទាប់ពីសំរាលកូនរួចត្រូវបានច្បាប់តំរូវអោយស្រាយបួស រួចត្រូវសងតាមចំនួនថ្ងៃដែលបានស្រាយកន្លងមក ។

- ចំពោះស្ត្រីមានផ្ទៃពោះ ឬមានជំងឺទឹកនោមផ្អែម ឬជាអ្នកបំបៅកូន គឺត្រូវបានច្បាប់អនុគ្រោះអោយស្រាយបួសបាន តែត្រូវសងវិញ ។



## ប្រការដែលនាំអោយខូចបួស

១- បញ្ចូលអ្វីមួយទៅក្នុងបំពង់កដោយចេតនា ។

២- ធ្វើអោយក្អួតដោយចេតនា ។

៣- ធ្វើអោយមានទឹកកាមចេញមកដោយចេតនា( មិនមែនដោយការរួមរ័ក) ។

៤- ការរួមរ័កជាមួយប្រពន្ធក្នុងពេលកាន់តំណមបួស( ពេលថ្ងៃ) ។

៥- មានឈាមរដូវនិងឈាមបន្ទាប់ពីសំរាលកូនរួចក្នុងពេលកំពុងបួស ។

៦- ការបញ្ចូលអ្វីមួយតាមទ្វារក្រោយដែលមិនមែនជាលក្ខណៈថ្នាំសំរាប់ព្យាបាល ។

៧- ការបញ្ចូលទឹកតាមច្រមុះ ។

៨- វិកលចរិកមួយថ្ងៃពេញ( ចាប់ពីមុនហ្វើជើររហូតដល់ថ្ងៃលិច) ។

៩- សន្លប់មួយថ្ងៃពេញ ។

១០-ការងាកចេញពីសាសនាឥស្លាមដោយចេតនា ។

## ប្រការដែលមិននាំអោយខូចបួស

១- ភ្លក្សអាហារដើម្បីអោយដឹងរសជាតិ រួចខ្ជាក់ចេញវិញ ។

២- ស្រង់ក្លិនពីអ្វីដែលច្បាប់មិនហាមឃាត់ ។

៣- ការទទួលទានអាហារឬផឹកដោយភ្លេចខ្លួន តែត្រូវបញ្ឈប់ជាបន្ទាន់

ពេលដឹងខ្លួនវិញ ។

៤- ការបន្តក់ថ្នាំចូលក្នុងភ្នែក ។

៥- ការចាក់ថ្នាំសំរាប់ព្យាបាល លើកលែងតែការប្រើថ្នាំកំលាំង។

៦- ការដុសសំអាតធ្មេញ ទោះបីប្រើថ្នាំដុសធ្មេញក៏ដោយចុះ ។

៧- ការមុជទឹកសំអាតខ្លួន តែតំរូវអោយមានការប្រុងប្រយ័ត្នពីទឹកចូលច្រមុះនិងត្រចៀក។

៨- ការដេកមួយថ្ងៃពេញ លើកលែងតែគេមានបំណង់ដេកបង្ហួសសឡាហ៍ប៉ុណ្ណោះ ។

៩- ការជប់ខ្យល់ឬបូមឈាមដើម្បីពិនិត្យមើលមេរោគ។

-លោកអាហ្ពូហ៊ូរ៉យរ៉ោះបាននិយាយថា: បុរសម្នាក់បានសួររ៉ស៊ូលុលឡោះពីពីរឿងអ្នកបួសប្រលែងលេងជាមួយប្រពន្ធ?រ៉ស៊ូលុលឡោះបានបញ្ជាក់ប្រាប់ថាគ្មានបញ្ហាអ្វីឡើយ ។ក្រោយមកក៏មានអ្នកមកសួរលោកម្នាក់ផ្សេងទៀតពីបញ្ហានោះដដែល តែត្រូវបានរ៉ស៊ូលុលឡោះធ្វើការហាមឃាត់ ។

អ្នកដែលរ៉ស៊ូលុលឡោះបានអនុគ្រោះ គឺវ័យចំណាស់និងអ្នកដែលរ៉ស៊ូលុលឡោះហាមឃាត់គឺជាយុវជន ។

*រាយការណ៍ដោយអ៊ីម៉ាំអាហ្ពូឌើវូតនិងប៉ៃហ្ពហ៊ីគី*



## ហាឌីស្សបញ្ជាក់ពីឧត្តមភាពនៃការបួស

- លោកអាប់ឌុលឡោះកូនអ៊ូមើរបាននិយាយថា: ណាហ្ពីបានមានប្រសាសន៍ថា:ពួកយើងជាប្រជាជនល្ងង់មិនចេះសរសេរនិងមិនចេះគូសវាសអ្វីទេ តែចំនួនថ្ងៃក្នុងខែគឺវាយ៉ាងនេះ( លោកលើកដៃធ្វើជាសញ្ញាដែលមានន័យថា) ២៩ថ្ងៃឬទៀត៣០ថ្ងៃ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហ្ពូខរី )*

- លោកអាប់ឌុលឡោះកូនអ៊ូមើរបាននិយាយថា:ណាហ្ពីបានមានប្រសាសន៍ថា: ក្នុងមួយខែអាចមាន២៩យប់ ដូច្នេះពួកអ្នកមិនត្រូវចាប់ផ្តើមបួសទេលុះត្រាតែពួកអ្នកបានឃើញកូនខែសិន តែបើក្នុងករណីមានពពកបាំងពួកអ្នក ( មើលមិនឃើញ) ចូរពួកអ្នកបំពេញចំនួនអោយបាន៣០ថ្ងៃ ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហ្ពូខរី )*

-លោកអាហ្ពូហ៊ូរ៉យរ៉ោះបាននិយាយថា: ណាហ្ពីបានមានប្រសាសន៍ថា:ម្នាក់ណាក៏ដោយក្នុងចំណោមពួកអ្នកមិនត្រូវបួសមុនចូលខែរ៉ម៉ាដនមួយថ្ងៃឬពីរថ្ងៃនោះឡើយ លើកលែងតែអ្នកនោះគេបានបួសបន្តមក គឺអោយគេបួសចុះ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហ្ពូខរី )*

- លោកអាប់ឌុលឡោះបាននិយាយថា:ពេលមួយពួកយើងនៅជាមួយណាហ្ពីពេលនោះលោកមានប្រសាសន៍ថា:ជនណាហើយមានលទ្ធភាព( ទ្រព្យសម្បត្តិនិងកំលាំងពលំ) ក្នុងការរៀបការ ចូរអោយគេរៀបការចុះ ព្រោះការរៀប

ការវាអាចបិតបាំងភ្នែកពីប្រការអាក្រក់និងអាចការពារពីការប្រព្រឹត្តពេស្យាចារ តែបើជនណាគ្មានលទ្ធភាពទេ ចូរអោយគេបួសវិញ ព្រោះការបួសវាអាចកាត់បន្ថយនូវតណ្ហា ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំប៊្ហូខរី)*

- លោកអៃយ៉ូបបាននិយាយថាៈ រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថាៈជនណាបានបួសពេញមួយខែរ៉ម៉ាដន បន្ទាប់មកគេបានបួសបន្ថែមប្រាំមួយថ្ងៃទៀត នៅខែសៅវ៉ាល គឺជននោះប្រៀបដូចជាគាត់បានបួសពេញមួយឆ្នាំ ។

*(រាយការណ៍ហាហ្ទីស្សដោយ អ៊ីម៉ាំមូស្លីម អាប៊្ហូឌើវូតនិងទៀរមីហ្សី)*

- លោកសាហាល់កូនសាអាត់បាននិយាយថាៈ ណាប៊្ហីបានមានប្រសាសន៍ថាៈ( មនុស្សស្ថិតក្នុងកុសលល្អពេលណាគេប្រញាប់ប្រញាល់ក្នុងការស្រាយបួស) ។ *(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហាហ្ទីស្សទាំង៥)*

- លោកអាប៊្ហូហ៊ូរ៉យរ៉ោះបាននិយាយថាៈរ៉ស៊ូលុលឡោះបានមានប្រសាសន៍ថាៈអល់ឡោះបានមានបន្ទូលថាៈ( យើងបានត្រៀមសំរាប់ខ្ញុំរបស់យើងដែលជាអ្នកធ្វើកុសលល្អនូវអ្វីដែលភ្នែកមិនដែលបានឃើញត្រចៀកមិនដែលបានលឺនិងចិត្តស្មានមិនដល់ ។ បើពួកអ្នកចង់ដឹងច្បាស់ចូរអានបន្ទូលរបស់អល់ឡោះដែលមានន័យថាៈ មនុស្សមិនអាចដឹងពីអ្វីដែលគេលាក់កំបាំងទុកអោយពួកគេពីចំណើចក្ខុឡើយ) ។*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំប៊្ហូខរី)*



- លោកអាត់ឌីកូនលោកហាទិមបាននិយាយថាៈ នៅពេលដែលអល់ឡោះបានបញ្ចុះវាក្យខណ្ឌថាៈ( ចូរអ្នកហូបចុករហូតដល់គំនួសណិសលេចចេញអោយអ្នកឃើញច្បាស់ពីគំនួសពណិខ្មៅ) ខ្ញុំបានយកខ្សែអ៊ុកល( ខ្សែពាក់លើក្បាលរបស់ជនជាតិអារ៉ាប់) ពណិខ្មៅដាក់ជិតខ្សែអ៊ុកលពណិសខាងក្រោមខ្នើយរបស់ខ្ញុំ ។ ខ្ញុំបានសង្កេតមើលនៅពេលយប់តែវាមិនបង្ហាញច្បាស់ដល់ខ្ញុំទេ ។ ខ្ញុំក៏ធ្វើដំណើរទៅរករ៉ស៊ូលុលឡោះពេលនោះខ្ញុំបានរំលឹករឿងនេះដល់លោក ។ លោកបាននិយាយថាៈ គំនួសពណិខ្មៅគឺសំដៅថាពេលយប់ និងគំនួសពណិសគឺសំដៅថាពេលថ្ងៃ ។ *(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំប៊្ហូខរី )*

- ហ្សៃតកូនសើហ្ពិតបាននិយាយថាៈ ពួកយើងបានទទួលទានអាហារបួស( ហូបបាយបួស) ជាមួយរ៉ស៊ូលុលឡោះ បន្ទាប់មកលោកបានក្រោកឈរដើរទៅសឡាហ៍ ។ពេលនោះគេបានសួរថាៈតើឃ្លាតគ្នាប្រហែលជាប៉ុន្មានរវាងការហូបបាយបួសនិងអាហ្សាន? ហ្សៃតបានឆ្លើយថាៈប្រហែលជាការសូត្រអាល់គួរអានចំនួន៥០វាក្យខណ្ឌ ។*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំប៊្ហូខរី)*

- អ្នកស្រីអាអ៊ីសះបាននិយាយថាៈពេលចូលដល់ដប់ថ្ងៃចុងក្រោយនៃខែបួសរ៉ម៉ាដនណាប៊្ហីបានរឹតបន្តឹងចង្កេះខោរបស់ខ្លួនលោកបង្កើនការគោរពសក្ការៈនៅពេលយប់ និងលោកបានដាស់ក្រុមគ្រួសាររបស់លោក ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហាហ្ទីស្សទាំង៥)*

- អ្នកស្រីអាអ៊ីសះបាននិយាយថាៈ ពេលចូលដល់ដប់ថ្ងៃចុងក្រោយនៃខែ

បួសរ៉ម៉ាដន ណាហ្គីតែងតែដើរប្រាប់អ្នកជិតខាងថា: ចូរពួកអ្នកស្វះស្វែងរកយប់កឡើរ (យប់ដ៏ថ្កុំថ្កើង) នៅក្នុងដប់ថ្ងៃចុងក្រោយនៃខែរ៉ម៉ាដន ។
*(រាយការណ៍ហាហ្ទីស្សរដោយអ៊ីមុាំហ្គូខរីនិងទៀរមីហ្សី )*

- អ្នកស្រីអាអ៊ីសះនិងអ្នកស្រីអ៊ុំមីសើឡើម៉ះបាននិយាយថា: ថ្ងៃមួយរ៉ស៊ូលុលឡោះក្រោកពីដំណេកចំពេលសឡាហ៏ស៊ូហ្គុះក្នុងពេលនោះលោកមានជូនុបជាមួយប្រពន្ធរបស់លោក។ លោកបានមុជទឹកសំអាតខ្លួន ហើយក៏បន្តបួសទៅ។ *(រាយការណ៍ហាហ្ទីស្សរដោយអ៊ីមុាំហ្គូខរី)*

- លោកអាហ្គូហ៊ូរយរ៉ោះបាននិយាយថា: មានថ្ងៃមួយនៅពេលដែលពួកយើងកំពុងអង្គុយជាមួយរ៉ស៊ូលុលឡោះស្រាប់តែមានបុរសម្នាក់បានរ៉ាយរ៉ាប់ប្រាប់រ៉ស៊ូលុលឡោះថា:ឱរ៉ស៊ូលុលឡោះ! អន្តរាយហើយ។ ពេលនោះរ៉ស៊ូលុលឡោះបានសួរបញ្ជាក់ថា:មានរឿងស្អី ?បុរសនោះបានប្រាប់ថា:ខ្ញុំបានរួមសង្វាសជាមួយប្រពន្ធរបស់ខ្ញុំនៅពេលថ្ងៃនៃខែរ៉ម៉ាដនដោយខ្ញុំកំពុងតែបួស។ រ៉ស៊ូលុលឡោះបានសួរបញ្ជាក់ថា: តើអ្នកមានខ្ញុំបំរើដែលអ្នកអាចលួសអោយមានសេរីភាពទេ? បុរសនោះបានឆ្លើយថា: ខ្ញុំគ្មានលទ្ធភាពលួសទេ។ រ៉ស៊ូលុលឡោះបានសួរបញ្ជាក់ទៀតថា: តើអ្នកអាចបួសពីរខែជាប់គ្នាបានដែរឬទេ? បុរសនោះឆ្លើយថា: ខ្ញុំគ្មានលទ្ធភាពទេ។ រ៉ស៊ូលុលឡោះបានសួរបញ្ជាក់ ទៀតថា: តើអ្នកអាចមានលទ្ធភាពផ្តល់ចំណីអាហារដល់អ្នកក្រីក្រចំនួន៦០នាក់ដែរឬទេ? បុរសនោះឆ្លើយថា:ខ្ញុំគ្មាន



លទ្ធភាពទេ។ បុរសនោះនៅស្ងៀមក្បែររ៉ស៊ូលុលឡោះ ហើយពួកយើងទាំងអស់គ្នាក៏នៅស្ងៀមដែរ ស្រាប់តែមានបុរសម្នាក់ផ្សេងទៀតយកផ្លែហ៊ូរម៉ាទំងន់៦០សក(មួយសក ស្មើនឹង២.៤គីឡូក្រាម) អោយរ៉ស៊ូលុលឡោះ។ ពេលនោះរ៉ស៊ូលុលឡោះបានសួរថា: អ្នកសួរខ្ញុំអម្បាញ់មិញនៅឯណា? បុរសនោះឆ្លើយថា: ខ្ញុំនៅទីនេះ។ រ៉ស៊ូលុលឡោះបាននិយាយថា:ចូរយកផ្លែហ៊ូរម៉ានេះទៅបរិច្ចាគចុះ(ផ្តល់ជាចំណីអាហារដល់អ្នកក្រីក្រចំនួន៦០នាក់) ។ បុរសនោះបាននិយាយទៅកាន់រ៉ស៊ូលុលឡោះថា:ឱរ៉ស៊ូលុលឡោះតើមានអ្នកណាក្រជាងខ្ញុំទៀត! ខ្ញុំសូមស្បថនឹងអល់ឡោះចុះថាពីផ្ទះរបស់ខ្ញុំទៅកន្លែងផ្សេងមួយទៀត(សំដៅទៅផ្ទះអ្នកផ្សេង) មានអ្នកណាក្រជាងក្រុមគ្រួសាររបស់ខ្ញុំដែរឬទេ? ពេលនោះរ៉ស៊ូលុលឡោះបានសើចរហូតដល់ឃើញធ្មេញខាងមុខ បន្ទាប់មកលោកបាននិយាយថា:បើអញ្ចឹងយកវាទៅផ្គត់ផ្គង់គ្រួសាររបស់អ្នកចុះ ។ *(រាយការណ៍ហាហ្ទីស្សរដោយ អ៊ីមុាំហ្គូខរី)*

- អ្នកស្រីមូអាហ្សះបាននិយាយថា:ខ្ញុំបានសួរអ្នកស្រីអាអ៊ីសះថា: តើហេតុផលយ៉ាងម្តេចសំរាប់អ្នកមានឈាមរដូវត្រូវគេប្រើអោយសងបួសតែមិនត្រូវគេប្រើអោយសងសឡាហ៏នោះ?អ្នកស្រីអាអ៊ីសះបានឆ្លើយថា:ពួកយើងធ្លាប់ជួបនូវបញ្ហាទាំងនេះ ហើយគេប្រើអោយពួកយើងសងការបួស តែគេមិនប្រើពួកយើងអាយសងការសឡាហ៏ឡើយ ។
*(រាយការណ៍ហាហ្ទីស្សរដោយអ៊ីមុាំហាហ្ទីស្សរទាំង៥)*

- លោកជើហ្ពៀរកូនអាប់ឌុលឡោះបាននិយាយថាៈ ពេលមួយក្នុងពេលធ្វើដំណើររបស់រ៉សូលុលឡោះលោកឃើញមានការប្រជ្រៀតគ្នានិងបានឃើញបុរសម្នាក់កំពុងជ្រកម្លប់។ លោកបានសួរថាៈ តើបុរសនោះត្រូវអ្វី? ពួកគេបាននិយាយប្រាប់ណាហ្ពីថាៈ គាត់កំពុងបួស ។ ពេលនោះណាហ្ពីមានប្រសាសន៍ថាៈ មិនចាត់ទុកជាការល្អទេ ការបួសក្នុងពេលធ្វើដំណើរនោះ ។ *(រាយការណ៍ហាហ្ពីស្សដោយអ៊ីម៉ាំហ្ពូខរី)*

-អ្នកស្រីអាអ៊ីសះបាននិយាយថាៈរ៉សូលុលឡោះមានប្រសាសន៍ថាៈជនណាបានស្លាប់ហើយគាត់នៅជំពាក់ការបួសគឺវ៉ាលីរបស់គាត់ត្រូវបួសសងអោយគាត់។ *(រាយការណ៍ហាហ្ពីស្សដោយអ៊ីម៉ាំហ្ពូខរី)*

- លោកអាប់ឌុលឡោះកូនអាប់ហ្ពើសបាននិយាយថាៈបុរសម្នាក់បានមកជួបណាហ្ពីរួចនិយាយថាៈឱរ៉សូលុលឡោះ! ម្តាយរបស់ខ្ញុំបានស្លាប់ហើយ ហើយគាត់បានជំពាក់ការបួស តើខ្ញុំត្រូវបួសសងជំនួសគាត់ដែរឬទេ? លោកបានឆ្លើយថាៈបាទ គឺអ្នកត្រូវបួសសងជំនួសគាត់។ បំណុលរបស់អល់ឡោះត្រូវតែសង។ ( *រាយការណ៍ហាហ្ពីស្សដោយអ៊ីម៉ាំហ្ពូខរី)*

- លោកអាហ្ពីជូហៃហ្វះបាននិយាយថាៈណាហ្ពីបានណែនាំរវាងសាល់ម៉ាននិងអាហ្ពូហ្ជើរហ្ជើអោយក្លាយជាពោះមួយនឹងគ្នា។ ក្រោយមកសាល់ម៉ានបានទៅលេងអាហ្ពូហ្ជើរហ្ជើ ក៏បានជួបនឹងប្រពន្ធអាហ្ពូហ្ជើរហ្ជើក្នុងសភាពរយ៉េរយៃ៉ពេលនោះសាល់ម៉ានបានសួរថាៈមានរឿងអ្វី? អ្នកស្រីបានឆ្លើយ



ថាៈ គឺអាហ្ពូហ្ជើរហ្ជើ លែងខ្វល់រឿងលោកីយ៍អស់ហើយ! ។ ក្រោយមកអាហ្ពូហ្ជើរហ្ជើបានមកដល់ក៏បានរៀបចំអាហារអោយសាល់ម៉ាន។ សាល់ម៉ានបានហៅអាហ្ពូហ្ជើរហ្ជើថាៈមកទទួលទានជាមួយគ្នា? អាហ្ពូហ្ជើរហ្ជើបានឆ្លើយថាៈ ខ្ញុំកំពុងបួស ។ សាល់ម៉ានបានតបវិញថាៈ ខ្ញុំនឹងមិនទទួលទានទេ លុះត្រាអ្នកទទួលទានជាមួយខ្ញុំដែរ។ ពេលនោះអាហ្ពូហ្ជើរហ្ជើក៏ព្រមទទួលទានទៅ។ លុះដល់ពេលយប់អាហ្ពូហ្ជើរហ្ជើក៏ ចាប់ផ្តើមសឡាហ៏ ពេលនោះសាល់ម៉ានប្រាប់ថាៈដេកភ្លាម គាត់ក៏ដេកក្រោយមកក៏ស្ទុះទៅសឡាហ៏ទៀត សាល់ម៉ានប្រាប់ទៀតថាៈ ដេកភ្លាម គាត់ក៏ដេក។ លុះពេលទៀបភ្លឺសាល់ម៉ានបានហៅអាហ្ពូហ្ជើរហ្ជើថាៈក្រោកឡើង ហើយក៏សឡាហ៏ទាំងពីរនាក់ទៅ។ ចប់សឡាហ៏សាល់ម៉ានបានប្រាប់អាហ្ពូហ្ជើរហ្ជើថាៈអ្នកមានភារកិច្ចត្រូវបំពេញចំពោះម្ចាស់របស់អ្នក ដូចនេះ ចូរអ្នកបំពេញរាល់ភារកិច្ចទៅតាមកន្លែងរបស់វា។ បន្ទាប់មកសាល់ម៉ានបានដើរមករកណាហ្ពីរួចបាននិយាយរឿងនេះប្រាប់ដល់លោក ពេលនោះណាហ្ពីមានប្រសាសន៍ថាៈត្រឹមត្រូវហើយអ្វីដែលសាល់ម៉ានបាននិយាយានោះ។

*(រាយការណ៍ហាហ្ពីស្សដោយអ៊ីម៉ាំហ្ពូខរី)*

**d u c**

# អៀកទីកាហ្វ

<u>អៀកទីកាហ្វ:</u> មានន័យថារក្សាការស្ថិតនៅក្នុងម៉ាស្ជិតដោយនៀតធ្វើការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ ។

*អ៊ីម៉ាំអះម៉ាត់បាននិយាយថា:* សាសនវិទូម្នាក់ៗថាវាជាប្រការស៊ូណាត់ ។ លោកហ្សូរីបាននិយាយថា:គួរអោយចំឡែកសំរាប់អ្នកកាន់សាសនាឥស្លាម! ពួកគេបានបោះបង់អៀកទីកាហ្វ ក្នុងពេលដែលរ៉ស៊ូលុលឡោះមិនដែលបោះបង់អៀកទីកាហ្វតាំងពីលោកមកដល់ទីក្រុងម៉ាឌីណះរហូតដល់លោកអស់សង្ខា ។

<u>ពេលវេលាអៀកទីកាហ្វ:</u> ជនណាបាននៀតអៀកទីកាហ្វនៅ១០ថ្ងៃចុងក្រោយក្នុងខែរ៉ម៉ាដនចាំបាច់លើជននោះត្រូវចូលក្នុងម៉ាស្ជិតក្នុងនាមជាអ្នកអៀកទីកាហ្វអោយបានមុនថ្ងៃលិចនៃថ្ងៃទី២០ ហើយអាចចេញវិញក្រោយពីថ្ងៃលិចនៃយប់រ៉យ៉ោ ។

<u>អៀកទីកាហ្វសំខាន់ :</u>

- ពេលណារ៉ស៊ូលុលឡោះមិនធ្វើដំណើរទេ លោកអៀកទីកាហ្វ១០ថ្ងៃចុងក្រោយនៃខែរ៉ម៉ាដន តែបើលោកធ្វើដំណើរលោកអៀកទីកាហ្វឆ្នាំខាងមុខចំនួន២០ថ្ងៃ ។
- រ៉ស៊ូលុលឡោះខកខានមិនបានអៀកទីកាហ្វម្តងក្នុងខែរ៉ម៉ាដន លោកក៏បានសងវាឡើងវិញក្នុងខែសៅវ៉ាល ។



- រ៉ស៊ូលុលឡោះបានអៀកទីកាហ្វក្នុងឆ្នាំដែលលោកទទួលមរណភាពចំនួន២០ថ្ងៃ ។

<u>ភាពងាយស្រួលរបស់អៀកទីកាហ្វ:</u>

- ពេលណាណាហ្គីចង់ អៀកទីកាហ្វ គេបានយកគ្រែនិងពូករបស់លោកដាក់ក្នុងម៉ាស្ជិតរបស់លោក ហើយគេរៀបចំអោយមានដំបូលបាំងជិតដើម្បីលោកស្នាក់នៅទីនោះក្រៅពេលសឡាហ៍ សំរាប់ការស្ងាត់ស្ងៀម ។

អ្នកស្រីអាអ៊ីសះបាននិយាយថា:ណាហ្គីបានអៀកទីកាហ្វ១០ថ្ងៃចុងក្រោយនៃខែរ៉ម៉ាដន ។ ខ្ញុំធ្លាប់រៀបចំដំបូលអោយលោក ។ ពេលលោកសឡាហ៍ស៊ូហ្គុះរួច លោកចូលទៅក្នុងនោះ ។

- រ៉ស៊ូលុលឡោះស្នាក់នៅក្នុងម៉ាស្ជិតមិនចេញក្រៅទេ លើកលែងតែក្នុងករណីចាំបាច់ដូចជាបន្ទោរបង់ជាដើម ។ អ្នកស្រីអាអ៊ីសះបាននិយាយថា: រ៉ស៊ូលុលឡោះពេលណាលោកអៀកទីកាហ្វ លោកមិនចូលផ្ទះទេ លើកលែងតែក្នុងករណីចាំបាច់បំផុត ។
- គេបានយកចំណីអាហារអោយរ៉ស៊ូលុលឡោះដល់កន្លែងតែម្តង ។
- រ៉ស៊ូលុលឡោះមិនបានទៅសួរសុខទុក្ខអ្នកជំងឺ ឬទៅហែរហមសាកសពទេក្នុងពេលដែលលោកអៀកទីកាហ្វដើម្បីចៀសវាងដាច់លក្ខណៈអៀកទីកាហ្វពេញលេញដើម្បីសុំជ័យជំនះពីអល់ឡោះម្ចាស់ ។

អ្នកស្រីអាអ៊ីសះបាននិយាយថា: ពេលមួយរ៉ស៊ូលុលឡោះបានដើរកាត់អ្នក

ជំងឺក្នុងពេលលោកអៀកទីកាហ្វ លោកដើរកាត់ធម្មតា ដោយមិនសួរនាំអ្វីឡើយ ។

អ្នកស្រីអ៊ីរវះបាននិយាយថាៈ ស៊ុណ្ណះសំរាប់អ្នកអៀកទីកាហ្វ គឺមិនត្រូវទៅសាកសួរសុខទុក្ខអ្នកជំងឺ ឬទៅហែរហមសាកសព ឬរួមសង្វាស់ជាមួយប្រពន្ធ ឬប្រលែងលេងជាមួយប្រពន្ធ និងមិនត្រូវចេញពីម៉ាស្ជិត លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ។ មិនចាត់ទុកថាអៀកទីកាហ្វទេ បើមិនបួស ហើយក៏មិនតំរូវអោយអៀកទីកាហ្វ ក្រៅពីម៉ាស្ជិតសំរាប់សឡាហ៏រួមដែរ។

## គោលបំណងនៃអៀកទីកាហ្វ១០ថ្ងៃចុងក្រោយ

១- ចង់ជួបយប់កឌើរ(យប់មួយដ៏ថ្កុំថ្កើងបំផុត)ៈ

វាជាគោលបំណងមួយធំបំផុតនៃអៀកទីកាហ្វរបស់រ៉ស៊ូលុលឡោះ គឺចាប់អៀកទីកាហ្វដំបូងពេញមួយខែ បន្ទាប់មកលោកអៀកទីកាហ្វ១០ថ្ងៃចំកណ្តាលខែដើម្បីចង់ជួបយប់ដ៏ថ្កុំថ្កើងនេះ តែក្រោយមកលោកយកតែ១០ថ្ងៃចុងក្រោយនៃខែរ៉ម៉ាដនសំរាប់អៀកទីកាហ្វ។

- លោកអាហ្គូសើអ៊ីដបាននិយាយថាៈ ពួកយើងបានអៀកទីកាហ្វជាមួយរ៉ស៊ូលុលឡោះនៅ១០ថ្ងៃចំកណ្តាលខែរ៉ម៉ាដន ។ លុះព្រឹកថ្ងៃទី២០ រ៉ស៊ូលុលឡោះបានដើរចេញរួចបានអានសុន្ទរកថាអោយពួកយើងស្តាប់នៅក្នុងបន្ទូលរបស់លោកថាៈខ្ញុំបានឃើញយប់កឌើរ ខ្ញុំក៏ភ្លេចវាទៅហើយ ដូច្នេះចូរពួក



អ្នកស្វះស្វែងនៅ១០យប់ចុងក្រោយក្នុងពេលសឡាហ៏វ៉ីទ្យេរ ។ខ្ញុំមើលឃើញថាៈរូបខ្ញុំនឹងឱនស៊ូជូតលើទឹកមានលាយដី ។ ជនណាហើយបានអៀកទីកាហ្វជាមួយរ៉ស៊ូលុលឡោះ ចូរអោយគេត្រឡប់ទៅវិញ។ ពួកយើងបានវិលត្រឡប់ទៅវិញ ពេលនោះពួកយើងមិនបានឃើញមានដុំពពកនៅលើមេឃទេ ស្រាប់តែពពកចាប់ផ្តើមប្រមូលផ្តុំគ្នា រួចក៏បង្អោរភ្លៀងមករហូតហូរកាត់ដំបូលម៉ាស្ជិត( ដំបូលម៉ាស្ជិតនៅពេលនោះជាធាងល្មើ) ពេលនោះសឡាហ៏បានចាប់ផ្តើម ខ្ញុំបានឃើញរ៉ស៊ូលុលឡោះឱនស៊ូជូតលើទឹកមានលាយដីរហូតខ្ញុំបានឃើញស្នាមដីនៅលើថ្ងាស់របស់លោក ។

២- ជំរះសំអាតចិត្តគំនិតៈពិតណាស់ជុំវិញការទទួលនូវកុសលល្អគឺអាស្រ័យទៅលើចិត្ត ដូចអ្វីដែលរ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ(នៅក្នុងខ្លួនមនុស្សមានសាច់មួយដុំពេលណាហើយដែលសាច់មួយដុំនោះជ្រះស្អាត(ពីអំពើបាបផ្សេងៗ)គឺខ្លួនប្រាណទាំងមូលក៏ជ្រះស្អាតដែរ តែបើសាច់មួយដុំនោះមិនជ្រះស្អាតទេ ខ្លួនទាំងមូលក៏មិនជ្រះស្អាតដែរ នោះគឺចិត្តមនុស្ស )។

ចំនុចដែលបំផ្លាញចិត្តគំនិតនោះគឺ ប្រការរំខានផ្សេងៗដែលនាំអោយភ្លេចនឹកគិតដល់អល់ឡោះជាម្ចាស់ ដូចជាការភ្លើតភ្លើនរឿងចំណីអាហារគ្រឿងផឹក អាពាហ៏ពិពាហ៏ និយាយច្រើនឥតប្រយោជន៏ ដេកច្រើន និងការហែហមឥតន័យ ចំនុចទាំងនេះហើយដែលធ្វើអោយចិត្តមនុស្សងាកចេញពីការនឹកគិតដល់អល់ឡោះម្ចាស់ ហើយវាអាចបំផ្លាញសង្គមរបស់គេក្នុងការគោរព

ប្រតិបត្តិនូវអ្វីដែលអល់ឡោះដាក់កាតព្វកិច្ចមក ។ ត្រង់នេះហើយទើបអល់ឡោះដាក់ចេញនូវការអនុវត្តដើម្បីរក្សាចិត្តគំនិតពួកយើងកុំអោយភ្លើតភ្លើនតាមចំនុចរៀបរាប់ខាងលើ នោះគឺ **អៀកទីកាហ្វ** ។

៣- រក្សាការបួសមិនអោយខូចៈលោកអះម៉ាត់កូនអាស៊ីមអាល់អាន់តគីបាននិយាយថាៈ( ពេលណាអ្នកចង់អោយចិត្តគំនិតបានជ្រះស្អាត ចូរអ្នកសុំពីអល់ឡោះអោយរក្សាអវៈយវៈរបស់អ្នក) ។

គ្មានឱកាសណាធំជាងឱកាសអៀកទីកាហ្វទេ ដើម្បីបានទទួលនូវគំនាប់នេះវាត្រូវតែចៀសអោយបានក្នុងការចងជាសត្រូវនឹងគ្នា ឈ្នានីសគ្នាឬនិយាយបោកប្រាស់គ្នា ដើម្បីគេចផុតពីប្រការទាំងនេះ ត្រូវតែសំអាតចិត្តគំនិតក្នុងពេលបំពេញកិច្ចការអៀកទីកាហ្វ ។

៤- ទំលាប់ការលះបង់ៈ

ក្នុងពេលអៀកទីកាហ្វមនុស្សដេកលើដី ទទួលទានអាហារក្នុងទ្រង់ទ្រាយសាមញ្ញ គេទទួលទានតែអ្វីដែលគេប្រទានអោយ ហើយគេមិនដែលទាមទាអ្វីដែលខ្លួនគ្មាននោះទេ ចំនុចទាំងនេះធ្វើអោយបុគ្គលនោះមានជ័យជំនះនោះគឺការលះបង់ ។ ការលះបង់ដូចអ្វីដែលលោកអ៊ុបនូតៃមីយ៉ាស់និយាយគឺ ការលះបង់អ្វីដែលមិនផ្តល់ប្រយោជន៍សំរាប់ថ្ងៃបរលោក ។

៥- ការសាកល្បងភាពស្មោះត្រង់ៈ

លោកហ្សុននូនបាននិយាយថាៈ( ខ្ញុំមិនដែលបានឃើញអ្វីមួយប្រសើរក្នុង



ពេលខ្ញុំព្យាយាមរកភាពស្មោះត្រង់ដូចនៅម្នាក់ឯងនោះឡើយ ។ បុគ្គលណាហើយដែលចូលចិត្តការស្ងៀមស្ងាត់ គឺគេបានភ្ជាប់ទៅនឹងសសរនៃការស្មោះត្រង់ហើយ) ។

ការស្ងាត់ស្ងៀម ប្រៀបនឹងទឹកដែលគេយកទៅស្រោចដើមឈើស្មោះនៅក្នុងចិត្ត ពេលណាហើយដែលអត់ទឹកវានឹងផុសចេញនូវការក្រអឺតក្រទមនិងបណ្តុះឡើងនូវការភ្ញាក់ផ្អើលមិនខាន ។ ដូចនេះហើយទើបលោកហ្គើកើរកូនអាមៀរនិយាយថាៈ ហេតុផលនេះហើយ ទើបគេមិនដែលឃើញលោកវ៉ហ្គៀកសំដែងការឆើតឆាយនៅក្នុងម៉ាស្ជិតនៃក្រុមរបស់លោក លើកលែងតែម្តងគត់ ។

លោកអាល់ហាសាន់អាល់ហ្គើសរីស្បថថាៈ( បើគេកំណត់មកអោយខ្ញុំសំដែងការឆើតឆាយដែលមិនអាចនរណាម្នាក់មើលឃើញពីអំណាចរបស់ខ្ញុំទេនោះច្បាស់ជាខ្ញុំធ្វើដោយសារការខ្លាចការក្រអឺតក្រទម) ។

មានអ្នកសាលាហ្វជាច្រើនពេញចិត្តអោយមនុស្សប្រុសលាក់បាំងខ្លះពីកុសលល្អ រហូតមិនអោយប្រពន្ធនិងអ្នកដទៃដឹងពីកិច្ចការទាំងនោះឡើយ ។

៦- ការរីករាយចំពោះការស្នាក់នៅក្នុងម៉ាស្ជិតៈ ម៉ាស្ជិតប្រៀបបានស្ថានទូតរបស់អល់ឡោះនៅលើផែនដី ។ បើស្ថានទូតនៃប្រទេសនីមួយចាត់ទុកជាកម្មសិទ្ធិរបស់ប្រទេសនោះ ហើយដែលត្រូវដើរតាមច្បាប់នៃប្រទេសរបស់ខ្លួនក្នុងពេលស្ថានទូតនៅក្នុងប្រទេសដ៏ទៃសោះនោះ ដូចគ្នាដែរម៉ាស្ជិតនៅ

លើផែនដី តែគ្រាន់តែម៉ាស្ជិតប្រៀបដូចជាដីមួយដុំដែលត្រូវគេដកចេញពីមេឃ ។

- ● ផលនៃការស្នាក់នៅក្នុងម៉ាស្ជិតៈអៀកទីកាហ្វ គឺអ្នកអាចបណ្តុះនូវអ្វីដែលអ្នកទាញយកផលក្រោយអៀកទីកាហ្វបាននោះគឺអ្នកដឹងក្នុងពេលអៀកទីកាហ្វពីអ្វីដែលវានឹងស្ថិតស្ថេរក្នុងផ្លូវជាមួយអ្នក ។ ពួកយើងជាភ្ញៀវរបស់អល់ឡោះនៅក្នុងម៉ាស្ជិត (ផ្ទះរបស់អល់ឡោះ) ដូចនេះភារកិច្ចរបស់ម្ចាស់ផ្ទះគប្បីយកចិត្តទុកដាក់លើភ្ញៀវពីសំណាក់ម្ចាស់ផ្ទះតាមលក្ខណៈសមរម្យរបស់ម្ចាស់ផ្ទះ ។ ដូចនេះបង្ហាញអោយឃើញថាៈ អ្នកនឹងទទួលបានផលពីការស្នាក់នៅក្នុងម៉ាស្ជិត ក្នុងពេលអ្នកអៀកទីកាហ្វឬក្រោយអៀកទីកាហ្វ ។

- អ្នកដែលបង្ហាត់ខ្លួនអោយចូលចិត្តការស្នាក់នៅក្នុងម៉ាស្ជិត គឺអ្នកបានបណ្តុះនៅក្នុងចិត្តរបស់អ្នកនូវគ្រាប់ពូជមួយ ដូចអ្វីដែលរ៉ស៊ូលុលឡោះបានបញ្ជាក់ពីសមាសភាពដែលមានសិទ្ធិជ្រកក្រោមម្លប់អារ៉ស្សរបស់អល់ឡោះនៅថ្ងៃបរលោកនោះគឺ( បុរសដែលចិត្តរបស់គេជិតជាប់នឹងម៉ាស្ជិត) ។

- ពិតណាស់អ្នកស្នាក់នៅក្នុងម៉ាស្ជិតរង់ចាំសឡាហ៍ គឺគេបានទទួលផលសឡាហ៍ ហើយម៉ាឡើអ៊ីកាហ៍ក៏បានសុំការសណ្តោសប្រណីពីអល់ឡោះដល់រូបជននោះដែរ ។

- ពិតណាស់ការស្នាក់ក្នុងម៉ាស្ជិតរយៈពេលយូរ គឺមានការសន្យាពីរ៉ស៊ូលុលឡោះថានឹងបាននៅក្បែរស្ថានឆ្ពោះទៅឋានសួគ៌ ។

- ការរង់ចាំពីសឡាហ៍មួយទៅសឡាហ៍មួយទៀតជាមូលហេតុក្នុងការលុបចោលនូវទោសកំហុសផ្សេងៗ ព្រមទាំងជាមូលហេតុសំរាប់លើកឋានៈផងដែរ ប្រៀបដូចអ្នកតស៊ូនៅជួរមុខដែរ ។

- ការប្រញាប់ប្រញាល់ក្នុងការទៅម៉ាស្ជិតដើម្បីអោយទាន់តឹកប៊ៀរជាមួយអ៊ីម៉ាំរ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈបុគ្គលណាហើយបានសឡាហ៍រួមទាន់អ៊ីម៉ាំចំនួន ៤០ថ្ងៃគេបានកត់ត្រាអោយ បុគ្គលនោះនូវការរួចទោសពីរចំនុចគឺរួចពីភ្លើងនរកនិងរួចផុតពីការពុតត្បុត ។

៧- ការតមអាហារបានមកដល់ហើយៈ

ចំណង់ចំណូលចិត្តដែលបាននិងកំពុងគ្របដណ្តប់ក្នុងសង្គមរបស់ពួកយើងគឺ : ការជក់បារី ការស្តាប់ចំរៀង ការព្យាយាមលើអំពើអាក្រក់ភ្ជាប់ចិត្តស្រលាញ់តែទៅលើអ្វីមួយ និងការមើលប្រការហារ៉ាំនៅតាមប៉ុស្តិ៍ទូរទស្សន៍និងមានកិច្ចការផ្សេងៗទៀតជាច្រើនដែលសុទ្ធតែជាកិច្ចការដែលរុញអោយមនុស្សលោកធ្លាក់ទៅក្នុងសភាពជាខ្ញុំបំរើនៃចំណង់តណ្ហា ដែលទីបញ្ចប់បិសាចជាអ្នកគ្រប់គ្រងទាំងស្រុង។ ត្រង់ចំនុចនេះហើយ ដែលបង្ហាញថា ពេលវេលាអៀកទីកាហ្វគឺដើម្បីស្រោចស្រង់អ្នកមានជំនឿអោយរួចផុតពីមេរោគនៃក្តីមហន្តរាយទាំងនោះក្រោយពីមានការសាកល្បងរបស់អល់ឡោះមកលើយុវជននៃប្រជាជនជំនាន់នេះ ដើម្បីបញ្ចូលពន្លឺទៅក្នុងចិត្តគំនិតរបស់ពួកគេ

ចៀសអោយផុតពីភាពឯងឹតសូន្យឈឹងដែលនឹងអាចមានសន្តិភាព និងភាពស្ងប់ស្ងៀមពេលនោះហើយដែលធ្វើអោយខ្លួនអាចទទួលបាននូវរសជាតិនៃការមានជំនឿជាលើកដំបូង ។

- ផ្តាច់រសជាតិឆ្ងាញ់: ដើម្បីជួយអោយអ្នកអៀកទីកាហ្វកាត់ផ្តាច់រសជាតិឆ្ងាញ់ គឺគេត្រូវតែស្នាក់នៅក្នុងម៉ាស្ជិតដោយមិនត្រូវចេញឡើយ ព្រោះអ្នកអៀកទីកាហ្វបើគេចេញក្នុងបំណងទិញរបស់ប្រគេន ឬចេញដើម្បីទៅលេងមិត្តភក្តិ គឺខូចហើយការអៀកទីកាហ្វនោះ ចុះទម្រាំបើគេចេញទៅដើម្បីជក់បារីឬមើលទូរទស្សន៍នោះ!!! ? ដូចនេះបើពេលណាអ្នកអៀកទីកាហ្វចេញដោយគ្មានមូលហេតុ ខូចហើយអៀកទីកាហ្វរបស់គេ ហើយវាកាន់តែធ្ងន់ធ្ងរទៅទៀត បើគេចេញដំណើរទៅក្នុងបំណងប្រព្រឹត្តអំពើខុសឆ្គងនោះ ដូច្នេះអៀកទីកាហ្វបានបង្ហាញអោយឃើញថា វាជាឱកាសដែលមានតំលៃបំផុតដើម្បីជំរះសំអាតពីសេចក្តីស្រេកឃ្លាននេះ អ្នកអាចបង្កើតប្រវត្តិសាស្ត្រថ្មី និងបើកទំព័រសករាជថ្មីជាមួយអល់ឡោះជាម្ចាស់ ។

៨- សាលាអត់ធ្មត់: បងប្អូនមូស្លីមជាទីស្រលាញ់! ដើម្បីរក្សាខ្លួនប្រាណរបស់អ្នក គឺតំរូវអោយអ្នកហាត់ពត់លត់ដំខ្លួន ហើយការហាត់ពត់លត់ដំខ្លួនគឺទាមទានូវការអត់ធ្មត់ជាចាំបាច់។ ដូចនេះវាគ្មានឱកាសណាច្រើនសំរាប់ការអត់ធ្មត់ដូចនៅពេលអៀកទីកាហ្វឡើយ ព្រោះនៅពេលអៀកទីកាហ្វវាមាន:



- ការអត់ធ្មត់ពីការបាត់បង់អ្វីដែលខ្លួនចូលចិត្តក្នុងចំណោមចំណីអាហារផ្សេងៗ ដែលខ្លួនធ្លាប់ទទួលទាននៅលំនៅដ្ឋានរបស់ខ្លួន ។
- ការអត់ធ្មត់ពីការដេកស្រួលដែលខ្លួនធ្លាប់មាននៅតាមមូលដ្ឋានរបស់ខ្លួន ព្រោះនៅក្នុងម៉ាស្ជិតមិនអាចមានគ្រែ ពូកខ្នើយដូចនៅក្នុងផ្ទះរបស់ខ្លួនឡើយ។
- ការអត់ធ្មត់ពីអ្វីដែលគ្មាននៅក្នុងម៉ាស្ជិតអំពីការលេងសើចនិងការរំខានពីសំណាក់អ្នកផ្សេងមកលើខ្លួន។
- អត់ធ្មត់ពីសេចក្តីស្រេកឃ្លានផ្នែកកាមតណ្ហាជាមួយប្រពន្ធ ។

៩- តាំងសមាធិចំពោះអល់ឡោះ: ត្រូវធ្វើគំលាតពីមនុស្សតាមដែលអាចធ្វើទៅបាន ដើម្បីបំពេញកិច្ចស្ងប់ស្ងាត់អារម្មណ៍និងការគោរពសក្ការចំពោះអល់ឡោះម្ចាស់និងសុំការការពារពីទ្រង់ ព្រោះថាដំណាក់កាលដំបូងគឺការស្ងប់ស្ងៀមអារម្មណ៍ ដូចអ្វីដែលរ៉សូលុលឡោះបានចាប់ផ្តើមគឺការនៅស្ងប់ស្ងាត់តែម្នាក់ឯង ពោលគឺលោកនៅស្ងាត់ម្នាក់ឯងនៅក្នុងរូងហេរ៉ាក(នៅលើកំពូលភ្នំនួរ) ។

១០- អៀកទីកាហ្វមានអត្ថន័យជ្រាលជ្រៅ: លោកជៅហ្សីបានពន្យល់ពីផលប្រយោជន៍អៀកទីកាហ្វថា:វានាំអោយចិត្តស្ងប់ស្ងាត់ចំពោះអល់ឡោះម្ចាស់ ហើយអាចអោយផ្តាច់ចេញពីកិច្ចការលោកិយ៍ផ្សេងៗ ងាកមករកកិច្ចការចំពោះអល់ឡោះតែមួយគត់ ពោលគឺការសូត្រធម៌នឹកគិតអល់ឡោះ សំដែងការស្រលាញ់ចំពោះតែអល់ឡោះនិងការព្រមទទួលយក ដែលកន្លែងរបស់វាគឺ

នៅក្នុងចិត្ត។ បើគេអាចគ្រប់គ្រងចិត្តបាន គឺរាល់ការទុក្ខព្រួយនិងគ្រោះថ្នាក់ផ្សេងៗវាស្រាលដោយការសូត្រធម៌នឹកគិតចំពោះអល់ឡោះម្ចាស់ឬនឹងការនឹកគិតដល់អ្វីផ្សេង។ និយាយជារួម គឺគ្មានការសប្បាយណាជាងនេះឡើយនោះហើយជាអត្ថន័យរបស់អៀកទីកាហ្វ។

## **អ៊ីហ្វេីដ័តរបស់អ្នកអៀកទីកាហ្វ**

ការសូត្រធម៌នឹកគិតចំពោះអល់ឡោះគឺជាអ៊ីហ្វេីដ័តចំបង :

លោកអ៊ីបនូកយីមបានរៀបរាប់ពីសារប្រយោជន៏នៃការសូត្រធម៌នឹកគិតចំពោះអល់ឡោះមានចំនួន៨0សារប្រយោជន៏ ហើយដែលសំខាន់ក្នុងចំណោមនោះសំរាប់អ្នកអៀកទីកាហ្វគឺ:

១- កំលាំងពលំរបស់អ្នកអៀកទីកាហ្វ: លទ្ធផលនៃការរក្សាអោយបានខ្ជាប់ខ្ជួនក្នុងការសូត្រធម៌នឹកគិតចំពោះអល់ឡោះ គឺវាសងមកវិញនូវការចងចាំមួយយ៉ាងខ្លាំងក្លា ដែលវាអាចជួយដល់អ្នកអៀកទីកាហ្វនូវការបង្កើនទង្វើកុសលល្អថែមទៀតក្នុងថ្ងៃនោះ។

<u>អ្នកអៀកទីកាហ្វជាទីស្រលាញ់!</u> ទោះបីអ្នកចេញទៅធ្វើការនៅពេលថ្ងៃ ឬអ្នកអាចអៀកទីកាហ្វបានពេញលេញ ក៏អ្នកត្រូវការកំលាំងពលំថែរសំរាប់ការសូត្រធម៌នឹកគិតចំពោះអល់ឡោះជាចាំបាច់ដែរ !! ដូចនេះអ្នកមិនត្រូវភ្លេចនូវកំលាំងពលំដែលអ្នកមានក្នុងពេលអៀកទីកាហ្វនោះទេ ពីព្រោះថាបើក្រៅពីនេះ វាអាចរំខានដល់ការព្យាយាមរបស់អ្នក កាត់បន្ថយការតាំង



ចិត្តរបស់អ្នកដែលវាជាហេតុមិនអាចនាំអ្នកដល់គោលដៅបាន ។

ចូរក្រលេកមើលដំណើររឿងមួយនៅពេលដែលអ្នកស្រីហ្វាទីម៉ាស់បានស្នើរសុំរ៉ស៊ូលុលឡោះនូវអ្នកបំរើម្នាក់ ពេលនោះលោកបានប្រាប់ថា: តើឪពុកមិនបានប្រាប់កូនពីអ្វីដែលល្អជាងខ្ញុំបំរើទេឬ? នោះ គឺពេលកូនដាក់ខ្លួនដេកកូនសូត្រធម៌សំអាតអល់ឡោះចំនួន៣៣ដង( سبحان الله ) រួចសូត្រធម៌សរសើរទ្រង់ចំនួន៣៣ដង( الحمد لله ) និងសូត្រធម៌បន្ទំទ្រង់ចំនួន៣៤ដង( الله أكبر )ពេលនោះអ្នកស្រីបានឆ្លើយអរគុណឪពុកថា: ខ្ញុំយល់ព្រមនឹងអល់ឡោះ ហើយនិងរ៉ស៊ូលរបស់ទ្រង់ហើយ( អ្នកស្រីនិយាយពីរដង) ។

ដូចនេះបង្ហាញអោយឃើញថា: ជនណាហើយគេព្យាយាមលើចំនុចនេះអល់ឡោះនឹងផ្តល់កំលាំងទៅអោយគេទ្វេរដង ដែលជាហេតុនាំអោយការព្យាយាមនិងការតាំងចិត្តរបស់គេកាន់តែរឹងមាំឡើង ហើយកុសលផលបុណ្យក៏កើនទៅតាមនោះដែរ ។

ត្រង់ចំនុចនេះហើយដែលលោកអ៊ីបនូកយីមរំលឹករឿងមួយថា: ថ្ងៃមួយខ្ញុំបានទៅរកលោកសៃយុលអ៊ីស្លាមអ៊ីបនូតៃមីយ៉ាស់ តែពេលនោះលោកកំពុងសឡាហ៍ស៊ូហ្គុះ ក្រោយមកលោកអង្គុយសូត្រធម៌រំលឹកចំពោះអល់ឡោះរហូតស្ទើរតែអស់ពាក់កណ្តាលថ្ងៃបន្ទាប់មកគាត់បានងាកមករកខ្ញុំរួចនិយាយថា: នេះជាពេលព្រឹករបស់ខ្ញុំហើយ បើខ្ញុំមិនទទួលទានអាហារទេកំលាំងខ្ញុំខ្សោយ ។

២-	ការសូត្រធម៌នឹកគិតៈរ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ( ខ្ញុំសូមប្រាប់ពួកអ្នកនូវកុសលល្អសំរាប់ការអនុវត្តរបស់ពួកអ្នក វាជាការកោតសរសើរពីម្ចាស់របស់ពួកអ្នក វាខ្ពង់ខ្ពស់សំរាប់ឋានៈរបស់ពួកអ្នក ហើយវាប្រសើរសំរាប់ពួកអ្នកជាងការចំណាយមាសប្រាក់និងវាប្រសើរសំរាប់ពួកអ្នកជាងពេលដែលពួកអ្នកជួបសត្រូវដែលពួកអ្នកត្រូវធ្វើការកាប់សំលាប់ពួកសត្រូវ ហើយពួកសត្រូវធ្វើការកាប់សំលាប់មកលើពួកអ្នកវិញ នោះគឺការសូត្រធម៌នឹកគិតចំពោះអល់ឡោះម្ចាស់តែមួយគត់) ។

- លោកហ្សុនទូនបាននិយាយថាៈ បុគ្គលណាហើយដែលចិត្តនិងអណ្តាតរបស់គេរវល់នឹងការសូត្រធម៌នឹកគិតចំពោះអល់ឡោះ អល់ឡោះនឹងដាក់បញ្ចូលក្នុងចិត្តគំនិតរបស់គេនូវពន្លឺនៃចំណង់ ។

ការសូត្រធម៌នឹកគិតចំពោះអល់ឡោះមិនមែនមាត់ថា ហើយចិត្តមិនផ្តោតលើការសូត្រនោះទេ ។ការសូត្រធម៌នឹកគិតចំពោះអល់ឡោះដែលពិតប្រាកដនោះគឺត្រូវតាំងអារម្មណ៍អោយបាននឹងនរ ក្នុងន័យបន្ទំអល់ឡោះម្ចាស់ និងត្រូវជំរុញចិត្តអោយកោតខ្លាចអល់ឡោះតែមួយគត់ ។

ការសូត្រធម៌នឹកគិតចំពោះអល់ឡោះប្រភេទនេះហើយ ទើបដូចអ្វីដែលលោកសៃឃុលឥស្លាមអ៊ីបនូតៃមីយ៉ាស់បានលើកឧទាហរណ៍ប្រាប់ថា( ចិត្តក្នុងការសូត្រធម៌នឹកគិតនោះ ប្រៀបដូចជាទឹកនិងត្រី តើត្រីមានសភាពបែបណាបើពេលវានៅក្រៅទឹកនោះ?)



៣- សេចក្តីស្លាប់ជាការរំលឹកមួយៈរ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ( ទង្វើដែលល្អជាងគេសំរាប់អល់ឡោះ គឺពេលស្លាប់អណ្តាតរបស់គេសើមដោយការសូត្រធម៌នឹកគិតដល់អល់ឡោះម្ចាស់) ។

អណ្តាតសើម គឺសំដៅទៅលើការមានចលនាជាប់រហូតរបស់អណ្តាតក្នុងការសូត្រធម៌នឹកគិតនៅពេលដល់សង្ខា ពោលគឺវាជាផ្លែផ្កាមួយបង្ហាញពីការសូត្រ ធម៌ជាប់ជានិច្ច ព្រោះថាបុគ្គលណាហើយ បើពេលនៅរស់គេរក្សាលើប្រការ ណា ពេលស្លាប់ក៏ដូចគ្នាដែរ ។ អៀកទីកាហ្វគឺជាឱកាសល្អបំផុតសំរាប់ឈានដល់ការផ្សើមអណ្តាតដោយការសូត្រធម៌នឹកគិតចំពោះអល់ឡោះម្ចាស់ ។ <u>អ្នកអៀកទីកាហ្វជាទីស្រលាញ់!</u> ចូររក្សាកុសលល្អទាំងក្នុងពេលនិងក្រោយពេលអៀកទីកាហ្វ សង្ឃឹមថាពេលណាអ្នកដល់សង្ខានឹងបានដូចលោក<u>ខលីតកូនប្រុសរបស់លោកម៉ាក់ឌឺន</u>ដែលលោកតែងតែសូត្រធម៌ជំរះសំអាតចំពោះអល់ឡោះម្ចាស់៤០ពាន់ដងក្នុងមួយថ្ងៃ នេះមិនរាប់បញ្ចូលការសូត្រអាល់គួរអានឡើយ លុះពេលលោកស្លាប់ គេបានលើកលោកដាក់លើគ្រែ ហើយដៃរបស់លោកក្តោបជារាងដូចជាកំពុងសូត្រធម៌ជំរះសំអាតចំពោះអល់ឡោះដែរ !!!

<u>តើអ្នកបានបញ្ចប់ការសូត្រអាល់គួរអានបានប៉ុន្មានដងហើយ?</u>

- រ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ ចូរសូត្រអាល់គួរអានអោយបានចប់នូវរឿងរាល់ខែ ។ ចូរសូត្រអាល់គួរអានអោយបានចប់នូវរឿងរាល់២៥ថ្ងៃ ។

ចូរសូត្រអាល់គួរអានអោយបានចប់នូវរៀងរាល់១៥ថ្ងៃ។ ចូរសូត្រអាល់គួរអានអោយបានចប់នូវរៀងរាល់៧ថ្ងៃ ។ដោយឡែកចំពោះអ្នកសូត្រអាល់គួរអានចប់តិចជាង៣ថ្ងៃនោះគឺគាត់មិនយល់អ្វីឡើយ!!

អ្នកអៀកទីកាហ្វជាទីស្រលាញ់! តើអ្នកមានឆ្លៀតឱកាសក្នុងពេលអៀកទីកាហ្វដើម្បីពង្រឹងទំនាក់ទំនងរបស់អ្នកនឹងអាល់គួរអានដែរឬទេ? គេចាត់ទុកជាការធ្វេសប្រហែសមួយ បើក្នុងរយៈពេល១០ថ្ងៃនៃពេលអៀកទីកាហ្វគេសូត្របានតែមួយចប់អាល់គួរអាននោះ! តើអ្នកនៅធ្វើអ្វីក្នុងពេលអៀកទីកាហ្វ បើអ្នកមិនសូត្រអាល់គួរអានទេ ?

## ចំនុចសំខាន់ពិសេសសំរាប់ការសូត្រអាល់គួរអាន

លោកអ៊ីមុាំអាល់គួរទូប៊ីបាននិយាយថាៈ អ្នកសូត្រមិនត្រូវប៉ះពាល់អាល់គួរអានទេ ក្នុងករណីខ្លួនគ្មានវូឌុនោះ ដូចនេះអ្នកសូត្រត្រូវតែៈ

- សូត្រអាល់គួរអានក្នុងពេលខ្លួនជ្រះស្អាត( មានវូឌុ) ។
- ដុសធ្មេញនិងសំអាតមាត់ ។
- ស្លៀកពាក់អោយបានស្អាតបាត ចៀសពីសំលៀកបំពាក់ប្រលាក់គំរង់ ។
- បែរមុខសំដៅទិសគិបឡាត់ និងត្រូវបិតអាល់គួរអានពេលខ្លួនស្វាប ។
- សូត្រអាអ៊ូហ្សុប៊ីលឡើហ៊ីមីណាស់សៃតនន្នៀរ៉យ៉ីម នៅពេលចាប់ផ្តើម ។
- សូត្រប៊ីស្មិលឡើហៀរ៉ស់ម៉ាន នៀររ៉ហ៊ីម ។
- នៅពេលសូត្រមិនត្រូវឈប់ដោយសារពាក្យសំដីរបស់មនុស្សលោកឡើយ លើកលែងតែក្នុងករណីចាំបាច់ប៉ុណ្ណោះ ។
- ត្រូវសូត្រអោយត្រូវតួអក្សរ និងរក្សាក្បួនច្បាប់នៃការសូត្រអាល់គួរអាន ។
- ត្រូវស្វែងយល់ពីអត្ថន័យរបស់អាល់គួរអាន ។
- ត្រូវឈប់ចំវាក្យខណ្ឌដែលអល់ឡោះសន្យាផ្តល់អោយ ហើយធ្វើការបួងសួងសុំពីអល់ឡោះម្ចាស់ដើម្បីបានផលនោះ។
- ត្រូវឈប់ចំវាក្យខណ្ឌណាដែលអល់ឡោះបញ្ជាក់ពីទណ្ឌកម្ម ហើយធ្វើការបួងសួងសុំពីអល់ឡោះម្ចាស់ដើម្បីអោយទ្រង់បញ្ចៀសពីទណ្ឌកម្មនោះ។
- ពេលឈប់សូត្រមិនត្រូវទុកអាល់គួរអានអោយនៅចំហឡើយ និងមិនត្រូវដាក់អ្វីមួយលើអាល់គួរអានទេ។
- ត្រូវដាក់ចូលថតតុក្នុងករណីឈប់សូត្រ ឬដាក់លើអ្វីមួយ និងមិនត្រូវដាក់លើដីឡើយ ហើយឧស្សាហ៍ជូតសំអាតអាល់គួរអានផង។
- មិនត្រូវសូត្រអាល់គួរអានជាលក្ខណៈលំនាំច្រៀងដូចអ្វីដែលពពួកហ្វើសិក (ពួកអ្នកមានពុត) ធ្វើនោះឡើយ ។
- មិនត្រូវសូត្រអាល់គួរអានតាមផ្សារ ឬទីដែលប្រកបដោយអំពើអបាយមុខឡើយ ។
- មិនត្រូវសរសេរអាល់គួរអាននៅលើដី ឬលើជញ្ជាំងឡើយ ។

## តើការសូត្រលឿននិងសូត្រយឺតមួយណាប្រសើរជាង?

មតិភាគច្រើនយល់ថា ការសូត្រយឺតប្រសើរជាងការសូត្រលឿន ដោយ

ឡែកលោកអ៊ីបនូហាជើរបាននិយាយថាៈ បើតាមពិនិត្យជាក់ស្តែងបង្ហាញអោយឃើញថាៈ ទស្សនៈនីមួយៗមានចំនុចប្រសើរដូចគ្នា នេះបើការសូត្រលឿននោះដែលវាមិននាំដល់ការភ័ន្តច្រលំតួអក្សរ ច្រលំសំណូរវែងខ្លី ឬមិនច្រលំកន្លែងដែលចាំបាច់ត្រូវឈប់ទេ។ បើមានការប្រុងប្រយ័ត្នលើចំនុចខ្វះខាតនោះបាន គឺគ្មានការសូត្រមួយណាប្រសើរជាងមួយណាឡើយ ពោលគឺវាប្រសើរដូចគ្នា ។ អ្នកសូត្រយឺតប្រៀបបាននឹងអ្នកបរិច្ចាគទានសម្បត្តិមួយប្រភេទដែលមានតំលៃខ្ពស់ ហើយអ្នកសូត្រលឿនប្រៀបបាននឹងអ្នកបរិច្ចាគទ្រព្យសម្បត្តិច្រើនប្រភេទ ប៉ុន្តែតំលៃរបស់វាស្មើគ្នានឹងទ្រព្យសម្បិត្តមួយប្រភេទដែលមានតំលៃខ្ពស់ដែរ វាអាចថាទ្រព្យសម្បត្តិមួយប្រភេទមានតំលៃខ្ពស់ជាងទ្រព្យច្រើនប្រភេទ ឬវាអាចផ្ទុយពីនេះក៏ថាបានដែរ។

## ចូរពិនិត្យមើលការព្យាយាមរបស់ខ្លួន

ពេលណាអ្នកសូត្រអាល់គួរអានក្នុងពេលអៀកទីកាហ្វ ហើយអ្នកមានអារម្មណ៍ថាៈ ការមានជំនឿរបស់អ្នកក្រោយការព្យាយាមសូត្រអាល់គួរអានហើយដូចមុនការសូត្រអាល់គួរអានដែរ ពោលគឺមិនកើនអ្វីសោះ ករណីនេះអ្នកត្រូវបង្កើនការយកចិត្តទុកដាក់និងពិនិត្យខ្លួនប្រាណរបស់អ្នកឡើងវិញ រួចចាប់ផ្តើមបន្តទៀត ពោលគឺៈ

- អ្នកមិនត្រូវអស់សង្ឃឹមចំពោះការសូត្រអាល់គួរអានឡើយ ។

ការព្យាយាមគឺជាអ៊ីហ្គើដ័តរបស់ពេលវេលា។ គ្មានកន្លែង គ្មានពេលវេលា



គ្មានឱកាសល្អនិងចំណាយតិច ដើម្បីបានផលបុណ្យជាងបណ្តាថ្ងៃ(១០ថ្ងៃ) អៀកទីកាហ្វឡើយ ។

- បើអ្នកមិនបានទទួលនូវរសជាតិពីការព្យាយាមក្នុងពេលអៀកទីកាហ្វរបស់អ្នកទេ តើអ្នកអាចទទួលបាននូវរសជាតិនោះក្នុងពេលវេលាផ្សេងដែរឬទេ?

ដូចនេះពួកយើងសូមផ្តាំផ្ញើអ្នកនូវបណ្តាំថាៈ

ចូរអ្នកប្រុងប្រយ័ត្នចំពោះការប្រើសំលេងខ្លាំងៗ ពេលសូត្រអាល់គួរអាន ឬពេលសូត្រធម៌ទឹកគិតចំពោះអល់ឡោះម្ចាស់ទាំងពេលយប់និងពេលថ្ងៃក្នុងពេលអៀកទីកាហ្វរបស់អ្នក ដើម្បីកុំអោយរំខានដល់អ្នកដទៃក្នុងការព្យាយាមរបស់ពួកគេ និងដើម្បីកុំអោយសៃតនជ្រៀតចូលផង ។

## ចូរទន្ទេញអាល់គួរអានក្នុងរយៈពេល៦០ថ្ងៃ

លោកអាប់ឌុលរ៉ស់ម៉ានដៅសារីបានទទួលមរណភាពក្នុងឆ្នាំ១៣៩៩ម.ស(១៩៧៨គ.ស) លោកទន្ទេញអាល់គួរអានចាំក្នុងរយៈពេល៦០ថ្ងៃគត់ ពោលគឺនៅរៀងរាល់ថ្ងៃ លោលត្រូវទន្ទេញអោយចាំចំនួនពាក់កណ្តាលជូហ្ស (ជំពូក គឺប្រហែលជា៩ទំព័រអាល់គួរអាន)

ហេតុអ្វីបានជាងាយសំរាប់គាត់យ៉ាងនេះ? !!

លោកអាប់ឌុលរ៉ស់ម៉ានបានពណ៌ប្រាប់ថាៈ ខ្ញុំបានទន្ទេញអាល់គួរអានទាំងមូលចាំក្នុងរយៈពេល៦០ថ្ងៃប៉ុណ្ណោះ។ ខ្ញុំផ្តាច់ការជួបមនុស្សម្នា ខ្ញុំបិទទ្វារការិយាល័យរបស់ខ្ញុំ ខ្ញុំអត់ចេញក្រៅទេ លើកលែងតែពេលសឡាហ៍ប៉ុណ្ណោះ។

អ្នកអៀកទីកាហ្វជាទីស្រលាញ់!លោកអាប់ឌុលរ៉ស់ម៉ានបានផ្តាច់ចេញពីការជួបមនុស្សរយៈពេល៦0ថ្ងៃ   លោកបានទន្ទេញចាំអាល់គួរអានទាំងមូលចុះអ្នកវិញ! អ្នកបានអៀកទីកាហ្វរយៈពេល១0ថ្ងៃ តើអ្នកទន្ទេញអាល់គួរអានបានប៉ុន្មានដែរ?

សំលាញ់អើយ! បើនៅរៀងរាល់ថ្ងៃអៀកទីកាហ្វអ្នកទន្ទេញតែមួយទំព័រច្បាស់ជាពេលបញ្ចប់អៀកទីកាហ្វ អ្នកអាចចាំបានមួយជំពូកពុំខានឡើយ តែបើអ្នកបន្ថែមដល់ពីរទំព័រក្នុងមួយថ្ងៃ ច្បាស់ជាអ្នកបានពីរជំពូកនៅពេលបញ្ចប់អៀកទីកាហ្វ។    បុគ្គលណាហើយបង្កើនការធ្វើអ៊ីហ្គើដ័តចំពោះអល់ឡោះ    ទ្រង់នឹងបង្កើនកុសលអោយគេវិញពុំខានឡើយ  ។   បើដើរតាមគន្លងនេះ  នោះតំលៃអៀកទីកាហ្វរបស់អ្នកនឹងទទួលបានផ្លែផ្កា  និងសេចក្តីសុខកាន់តែកើនឡើង ។

## តើពាក្យអ្វីដែលល្អបន្ទាប់ពីអាល់គួរអាន?

រ៉ស៊ូលុលឡោះមានប្រសាសន៏ថាៈ ពាក្យពេចន៏ដែលល្អប្រសើរនោះគឺ

سُبْحَانَ اللهِ وَالْحَمْدُ لِلَّهِ  وَلاَ إِلَهَ إِلاَّ اللهُ وَاللهُ أَكْبَرُ

## ចូរសុំការអភ័យទោស!

រ៉ស៊ូលុលឡោះមានប្រសាសន៏ថាៈ( ជនណាហើយចង់បានការរីករាយពីកំណត់ត្រារបស់ខ្លួនចូរអោយគេសុំការអភ័យទោសពីអល់ឡោះអោយបានច្រើន) ។



មានការដាស់តឿនរំលឹករបស់ណាហ្គីលុកម៉ានដល់កូនរបស់លោកថាៈឱកូនជាទីស្រលាញ់! កូនត្រូវគ្រលាស់អណ្តាតរបស់កូនក្នុងការសុំការអភ័យទោសពីអល់ឡោះអោយបានច្រើន ព្រោះសំរាប់អល់ឡោះម្ចាស់មានពេលជាច្រើនដែលមិនបដិសេធចំពោះការសុំការអភ័យទោសឡើយ ។

ដូចនេះបង្ហាញអោយឃើញថាៈ រ៉ស៊ូលុលឡោះជាបុគ្គលមួយរូបដែលធ្វើការសុំការអភ័យយទោសពីអល់ឡោះជាច្រើន ដូចអ្វីដែលលោកមីកហ៊ុលបានលឺលោកអាហ្គួហ៊ូរ៉យរ៉ោះនិយាយថាៈ  ខ្ញុំមិនដែលបានឃើញអ្នកណាម្នាក់សុំការអភ័យទោសច្រើនជាងរ៉ស៊ូលុលឡោះឡើយ ។

ចំណែកឯលោកមីកហ៊្វូលវិញនិយាយថាៈ  ខ្ញុំមិនដែលបានឃើញអ្នកណាម្នាក់សុំការអភ័យទោសច្រើនជាងអាហ្គួហ៊ូរ៉យរ៉ោះឡើយ ។

ចំណែកឯមិត្តសំលាញ់របស់មីកហ៊្វូលវិញនិយាយថាៈ  លោកមីកហ៊្វូលធ្វើការសុំការអភ័យទោសពីអល់ឡោះយ៉ាងច្រើន ។

ជាការគួរអោយសរសើរខ្លាំងណាស់សំរាប់អ្នកទាំងនោះ        គឺពេលគេជួបហាហ្វីស្សណាមួយ   ទង្វើរបស់ពួកគេសំដែងមុនអណ្តាតទៅទៀត!  ការសុំការអភ័យទោសមានសារៈសំខាន់ណាស់ បើទោះបីបុគ្គលម្នាក់បានក្លាយជាសពរហូតអណ្តាតរបស់គេមិនអាចគ្រលាស់សុំការអភ័យទោសក្តី   ក៏បងប្អូនរបស់គេអាចធ្វើការងារនេះជំនួសបានដែរ ដោយយោងតាមការណែនាំរបស់រ៉ស៊ូលុលឡោះក្នុងប្រសាសន៏របស់លោកថាៈ  ចូរពួកអ្នកសុំការអភ័យទោសអោយពោះមួយរបស់អ្នកផងនិងសុំអោយគាត់មានអារម្មណ៏នឹងនក្នុងខ្លួន

ព្រោះគាត់នឹងត្រូវគេចោទសួរក្នុងពេលបន្តិចទៀតនេះហើយ( សំដៅទៅលើសពដែលត្រូវគេបញ្ចុះសពគ្រប់ហើយ) ។

## ការសុំការអភ័យទោសមានច្រើនប្រភេទ

ការសុំការអភ័យទោសរបស់អ្នកអៀកទីកាហ្វ គឺមិនដូចការសុំការអភ័យទោសរបស់អ្នកផ្សេងឡើយ ពោកគឺការសុំរបស់គេដើម្បីអោយរួចផុតពីទោសកំហុសដែលគេមានមួយឆ្នាំកន្លងមកដែលគេភ្លេចវា លុះពេលអៀកទីកាហ្វគឺជាពេលដែលគេរំលឹកវាឡើងវិញទាំងអស់ ប្រកបដោយការសោកស្តាយចំពោះទង្វើឆ្គាំឆ្គងទាំងនោះ មូលហេតុទាំងនេះធ្វើអោយគេហូរទឹកភ្នែកដោយការខ្លាចពីទណ្ឌកម្មរបស់អល់ឡោះ ដែលនាំអោយការសំរក់ទឹកភ្នែករបស់គេនេះប្រកបដោយពរជ័យពីអល់ឡោះម្ចាស់ ។

*ការសារភាពកំហុស ការងាកទៅរកម្ចាស់ ការតាំងចិត្តនិងការចង្អុលបង្ហាញ* មិនមែនធ្វើតែនៅក្នុងរ៉មាដនប៉ុណ្ណោះទេ ផ្ទុយទៅវិញក្រៅពីរ៉មាដនក៏ត្រូវតែព្យាយាមដែរ ។

<u>អ្នកអៀកទីកាហ្វទាំងឡាយ! តើឥឡូវនេះអ្នកបានដឹងពីអត្ថន័យរបស់អៀកទីកាហ្វហើយមែនទេ?</u>

## សឡាវ៉ាតលើណាប៊ី

ពេលអៀកទីកាហ្វគឺជាឱកាសងាយស្រួលមួយសំរាប់ការនៅស្ងាត់ស្ងៀមដែលអ្នកអាចសឡាវ៉ាតលើណាប៊ីរបស់អ្នកក្នុងន័យបានទទួលនូវអត្ថន័យ



ពេលលេញ ។

- ពេលអ្នកសឡាវ៉ាតលើណាប៊ីលើកទី១ ចូររំលឹកដល់សភាពរបស់ណាប៊ីពេលលោកត្រូវគេគប់នឹងដុំថ្មកាលនៅតំបន់តអ៊ីហ្វរហូតរបួសជើងទាំងពីររបស់លោក ហើយលោកជាបុគ្គលដែលត្រូវអល់ឡោះតែងតាំងដើម្បីអ្នកទាំងអស់គ្នា ។
- អ្នកសឡាវ៉ាតលើកទី២ រួចនឹកគិតដល់ពេលដែលគេយកពោះវៀនសត្វអូដ្ឋមកគប់ដាក់លើក្បាលរបស់លោក និងព្យាយាមច្របាច់កលោកសំលាប់នៅនឹងកាក់ហ្គះតែម្តង ហើយលោកជាបុគ្គលដែលត្រូវអល់ឡោះតែងតាំងដើម្បីអ្នកទាំងអស់គ្នា ។
- អ្នកសឡាវ៉ាតលើកទី៣ រួចនឹកគិតដល់ពេលដែលលោកត្រូវរបួសក្បាលក្នុងសម័យសង្គ្រាមនៅតំបន់អ៊ូហ៊ុដ ពេលនោះលោករបួសនិងមានការឈឺចាប់ជាខ្លាំង ចំពោះការសំលាប់គូកនដែលជាទីស្រលាញ់បំផុតរបស់លោក ហើយលោកជាបុគ្គលដែលត្រូវអល់ឡោះតែងតាំងដើម្បីអ្នកទាំងអស់គ្នា ។
- អ្នកសឡាវ៉ាតលើកទី៤ រួចនឹកគិតដល់ពេលដែលលោកបួងសួងសុំដើម្បីប្រជាជនលោក ហើយរូបអ្នកក៏ស្ថិតក្នុងចំណោមប្រជាជននោះដែរ មិនតែប៉ុណ្ណោះលោកយកចិត្តទុកដាក់មកលើពួកអ្នកខ្លាំងណាស់ ហើយលោកជាបុគ្គលដែលត្រូវអល់ឡោះតែងតាំងដើម្បីអ្នកទាំងអស់គ្នា ។

ឆ្លងតាមគុណបំណាច់ដ៏លើសលប់នេះហើយ អ្នកត្រូវបានច្បាប់តំរូវអោយសឡាវ៉ាតលើណាប៊ី និងត្រូវសំដែងការស្រលាញ់អោយអស់ពីដួងចិត្តរបស់

អ្នកនិងត្រូវប្រតិបត្តិតាមទាំងកាយវិការនិងពាក្យសំដី ពោលគឺអ្នកមិនត្រូវសូត្រសឡាវ៉ាតតែបបូរមាត់ ហើយចិត្តធ្វេសប្រហែសនោះឡើយ ព្រោះនេះជាគំនាប់ទ្រព្យដ៏មានតំលៃដែលមិនអាចកាត់ថ្លៃបានឡើយ ។

## អកុសលរបស់អ្នកអៀកទីកាហ្វ

មនុស្សដែលស្ថិតក្នុងការខឹងរបស់អល់ឡោះគឺ.........អ្នកអៀកទីកាហ្វ!!

រ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ （មនុស្សដែលទទួលកំហឹងពីអល់ឡោះជាងគេមានបីប្រភេទៈ

១- អ្នកងប់នឹងប្រការហារ៉ាំ( ប្រការដែលច្បាប់ឥស្លាមហាមឃាត់) ។

២- អ្នកដែលមានបំណងនាំយកមាគិរបស់ពួកជើហ៊ីលីយ៉ាស់ដាក់ចូលក្នុងសាសនាឥស្លាម ។

៣- អ្នកដែលចង់បង្ហូរឈាមគេទាំងខុសច្បាប់ ។

<u>អ្នកអៀកទីកាហ្វ!</u> អ្នកមានឱកាសពីរក្នុងពេលតែមួយគឺៈ

១- ពេលវេលាពិសិដ្ឋ នោះគឺ១០ថ្ងៃចុងក្រោយនៃខែរ៉ម៉ាឌន ។

២- ទីកន្លែងពិសិដ្ឋ នោះគឺម៉ាស្ជិត ។

ចូរប្រុងប្រយ័ត្នការគោរពចំពោះអល់ឡោះក្នុងផ្ទះរបស់ទ្រង់ក្នុងពេលអៀកទីកាហ្វរបស់អ្នករយៈពេល១០ថ្ងៃ អាចថាធ្វើខុសលើប្រការណាមួយ នឹងក្លាយទៅជាទីកំហឹងពីអល់ឡោះ ឬអាចថាក្លាយជាជនអាក្រក់ម្នាក់ ដោយ



សារតែគេស្មានថាគេជាមនុស្សល្អដាច់គេម្នាក់ តែផ្ទុយទៅវិញ បើគេប្រព្រឹត្តអំពើអកុសល គេនឹងក្លាយជាជនក្បត់នឹងម្ចាស់របស់គេពុំខាន ។

គេដាក់ឈ្មោះជំពូកនេះថាៈ អកុសលរបស់អ្នកអៀកទីកាហ្វ ដោយសារអ្នកអៀកទីកាហ្វប្រឈមនឹងគ្រោះថ្នាក់ដែលនាំអោយប៉ះពាល់ដល់អារម្មណ៍ក្នុងពេលអៀកទីកាហ្វនិងក្រោយពេលអៀកទីកាហ្វ ។ ចំនុចអកុសលនោះគឺៈ

១- ការនិយាយច្រើន ៈ

អ្នកមិនអាចហាត់ពត់លត់ដំអណ្តាតរបស់អ្នកមិនអោយនិយាយច្រើនក្នុងពេលផ្សេងដូចពេលអៀកទីកាហ្វឡើយ ។ ការនិយាយច្រើនជាចំនុចគ្រោះថ្នាក់មួយឈានដល់ការនិយាយពីប្រការហាមឃាត់( ប្រការហារ៉ាំ) ។ បុគ្គលណាហើយដែលអល់ឡោះការពារគេ គឺជននោះចៀសផុតពីការនិយាយច្រើនពុំខានឡើយ ។ រ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ(ដូចម្តេចដែលហៅថាការនិយាយច្រើន?)។ លោកអាត់ហ៊ិនអាហ្គីរ៉ហ្គើសបាននិយាយថាៈ ប្រជាជនមុនពួកអ្នក( ពួកសាហាហ្ព័តរ៉ស៊ូលុលឡោះ) មិនចូលចិត្តនិយាយច្រើនឡើយ គេចាត់ទុកការនិយាយច្រើនក្រៅពីអាល់គួរអាន ក្រៅពីមាគិរបស់រ៉ស៊ូលុលឡោះ ក្រៅពីការប្រើអោយមនុស្សធ្វើល្អនិងហាមឃាត់មនុស្សពីការធ្វើអំពើអាក្រក់ គឺជាប្រការមួយដែលត្រូវបានច្បាប់ហាមឃាត់ ។ ការនិយាយចេញនូវសេចក្តីត្រូវការក្នុងការរស់នៅដែលវាចាំបាច់នោះមិនជាអ្វីឡើយ ។ តើអ្នកទទួលស្គាល់ទេថាមានអ្នកកត់ត្រាអំពើល្អនិងអំពើអាក្រក់

នៅលើស្មាស្ដាំនិងស្មាឆ្វេង បើទោះបីជាពាក្យសំដីណាក៏ដោយ ក៏អ្នកកត់ត្រានោះនៅជិតបំផុតដែរ ?

តើម្នាក់ៗក្នុងចំណោមពួកអ្នកមានការខ្មាស់អៀនទេ ពេលដែលទំព័រកាសែតដែលគេបានសរសេរផ្សព្វផ្សាយនោះ គឺភាគច្រើនមិនមែនជាលក្ខណៈសាសនាឬលោកីយ៍ឡើយ ។

## ប្រការដែលមិនសក្តិសមសំរាប់អ្នកអៀកទីកាហ្វ

លោកអ៊ីប៉្រហ៊ីមកូនលោកស៊ូឡៃម៉ានបាននិយាយថា: ខ្ញុំបានអង្គុយជាមួយលោកសុហ្វយ៉ាន ពេលនោះបុរសម្នាក់បានសំលឹងមើលទៅសំលៀកបំពាក់របស់លោកសុហ្វយ៉ាន រួចសួរថា: ឱឪពុកអាប់ឌុលឡោះ(ងាររបស់លោកសុហ្វយ៉ាន) អាវនេះធ្វើពីអ្វី? លោកសុហ្វយ៉ានឆ្លើយថា: ពួកគេស្អប់ការនិយាយច្រើន ។

<u>អ្នកអៀកទីកាហ្វជាទីស្រលាញ់!</u> តើសមដែរឬទេ បើអ្នកជជែកគ្នារឿងកិច្ចការលោកីយ៍ក្នុងពេលដែលអ្នកមិនទាំងបានអៀកទីកាហ្វផងនោះ! រូបអ្នកគ្រាន់តែឈានជើងចេញពីលោកីយ៍តែប៉ុណ្ណោះ ។ ហេតុអ្វីបានជាអ្នកឆាប់ទទួលយកការជជែករវែកញែកពីកិច្ចការលោកីយ៍ដោយខ្លួនអ្នកកំពុងស្ថិតនៅក្នុងនាមជាអ្នកសំរួលអារម្មណ៏ចំពោះអល់ឡោះម្ចាស់នោះ?

តើការពិភាក្សារឿងរ៉ាវរបស់ប្រពន្ធកូន ប្រសើរជាងការសូត្រធម៌នឹកគិតចំពោះអល់ឡោះនិងការនៅស្ងៀមស្ងាត់ឬ ?



២- បរិភោគច្រើន:

<u>ពោះមួយជាទីស្រលាញ់!</u> ការទទួលទានអាហារតិចធ្វើអោយចិត្តនឹងន ធ្វើអោយការភ្លើតភ្លើនចុះខ្សោយ និងបង្ក្រាបកំហឹងបាន គឺវាប្រៀបនឹងការដោះលែងមនុស្សពីភាពខ្ជិលច្រអូស អោយមនុស្សចេះឱនលំទោន និងមិនព្រងើយកន្តើយ ។

<u>សំលាញ់!</u> ការមិនសូវយកចិត្តទុកដាក់ចំពោះចំណីអាហារច្រើនប្រភេទ និងមិនសូវខ្វល់រឿងចំណីអាហារ គឺអាចងាយសំរាប់អ្នកនៅពេលអៀកទីកាហ្វ។

ចូរស្ដាប់ខ្ញុំពីក្ដីបារម្ភបំផុតក្រៅខែរ៉ម៉ាដន ដែលយើងសូមដងស្រង់ពាក្យសំដីរបស់អាល់វ៉ាហ្វើកូនអាគីលដែលនិយាយថា:

( ខ្ញុំព្យាយាមសង្ខេបពេលវេលាបំផុតក្នុងពេលទទួលទានអាហាររបស់ខ្ញុំរហូតខ្ញុំជ្រើសរើសការទទួលទាននូវនំក្រៀបផ្អាប់ជាមួយនំប៉័ងលាយនឹងទឹកដើម្បីអោយងាយទំពាលេប។ ការទទួលទានប្រភេទនេះ វាសំរួលដល់ការអានអក្សរនិងទទួលបានផលដែលរូបខ្ញុំមិនធ្លាប់ជួប )។

សូមអល់ឡោះម្ចាស់ផ្ដល់ពរជ័យដល់អាហ្គូវ៉ាហ្វើផង ។

លោកបានធ្វើរបៀបនេះក្រៅខែរ៉ម៉ាដន ចុះក្នុងខែរ៉ម៉ាដនវិញ តើលោកបានធ្វើអ្វីខ្លះ ?

*អ្នកអៀកទីកាហ្វហេតុអ្វីបានជាអ្នកមានចំណាប់អារម្មណ៏លើបញ្ហាចំណីអាហារម្លេះ! ?*

តើអ្នកចង់កំទេចបិសាចនៅទីណាដែលវាមានបំណងចង់កំទេចអ្នកទេ? តើអ្នកចង់ផ្ចាញ់ផ្ចាលបិសាចនៅទីណាដែលវាមានបំណងផ្ចាញ់ផ្ចាលអ្នកទេ? ហើយអ្នកចង់បង្វិលអំពើធ្ងន់ទៅអោយមេធ្ងន់វិញដែរឬទេ? បើអ្នកមានបំណងយ៉ាងនេះមែន ចូរអនុវត្តតាមលោកអាល់អាសវ៉ាតកូនលោកអាល់អាសវ៉ាត ពេលលោកទទួលទាននំប៉័ងគឺលោកចេតនាផ្តោតទៅលើកុសលល្អ។ គេបានសួរអ្នកនាំដំណឹងនេះថា: ហេតុផលអ្វីបានជាគាត់ទទួលទាននំប៉័ង? អ្នកនាំដំណឹងនេះឆ្លើយថា: គឺគាត់ទទួលទាននំប៉័ងដើម្បីសុខភាព ពេលណាគាត់ពិបាកក្នុងការសឡាហ៍ គាត់បន្ថយការទទួលទានតែបើគាត់ចុះខ្សោយកំលាំងពេលគាត់បន្ថយការហូបចុក គាត់ក៏ទទួលទាននំប៉័ងដើម្បីអោយមានកំលាំងឡើងវិញ ពោលគឺលោកទទួលទានអាហារឬបន្ថយការទទួលទាន គឺដើម្បីកិច្ចការសឡាហ៍! ។

ដូចនេះបង្ហាញអោយឃើញថា: ការទទួលទានអាហារជាច្រកមួយសំរាប់ការគោរពសក្ការៈជំនួសអោយភាពខ្ជិលច្រអូស។ អ្នកមិនត្រូវធ្វេសប្រហែសមួយវិនាទីណាឡើយ ក្នុងពេលអៀកទីកាហ្វ សូម្បីក្នុងពេលទទួលទានអាហារក៏ដោយចុះ! ពេលអ្នកទទួលទាន អ្នកមិនត្រូវចេតនាណាក្រៅពីដើម្បីពង្រឹងសុខភាពសំរាប់ការប្រតិបត្តិសឡាហ៍និងបួសនោះឡើយ។

ពេលណាអ្នកទទួលទានអាហារតិចតួច ហើយបង្កើនការគោរពសក្ការៈ *ពេលនោះគំរូរបស់អ្នកប្រៀបបាននឹងលោកសុហ្វយ៉ានហើយ!*

លោកអាប់ឌុលវ៉ាហៀកដែលត្រូវជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំងអស់



របស់លោកសុហ្វយ៉ានបាននិយាយថា: ថ្ងៃមួយលោកសុហ្វយ៉ានបានមកលេងពួកយើង ខ្ញុំបានធ្វើម្ហូបជូនគាត់ គាត់បានទទួលទានទៅ។ ពេលទទួលទានរួចលោកក្រោកឈរឡើងទាញខោ អោយចំកណ្តាល បន្ទាប់មកលោកនិយាយថា: ឱអាប់ឌុលវ៉ាហៀកមានគេនិយាយថា: ចូរផ្តល់ចំណីអោយសត្វលារួចចាំប្រើវា ។ លោកនិយាយចប់ក៏ក្រោកឈរដើរទៅសឡាហ៍រហូតទល់ពេលស៊ូហ្ពុះតែម្តង។

៣- រាប់អានជ្រុលពេក:

<u>អ្នកអៀកទីកាហ្វជាទីស្រលាញ់!</u> មនុស្សភាគច្រើនញាណនឹងការរស់នៅជាក្រុមនិងការច្រលូកច្រលំគ្នា រហូតដល់បាត់បង់គំរូនៃកិច្ចប្រតិបត្តិចំពោះអល់ឡោះនិងធ្វើអោយពួកគេឃ្លាតឆ្ងាយពីភ្នែកមនុស្សម្នាផងដែរ ។ ការសេពគប់ជ្រុលពេកធ្វើអោយជ្រុលជ្រួសពាក្យសំដីផ្សេងៗ មិនតែប៉ុណ្ណោះវានាំអោយបិតច្រកនៃការសូត្រធម៌នឹកគិតចំពោះអល់ឡោះនិងបើកឡើងនូវច្រកនៃការប្រព្រឹត្តនូវអំពើអាក្រក់ ធ្វើអោយចិត្តគំនិតមានៈរឹងរូស បង្កជំលោះបង្កនូវការសង្ស័យផ្សេងៗ និងនាំអោយបាត់បង់ផលបុណ្យផងដែរ។ នេះបើគេអាចគេចផុតពីប្រការបំរាម ដូចជាការនិយាយដើមគេ ការធ្វើបុកទុក្ខម្នេញដល់អ្នកដទៃ និងប្រការអាក្រក់ផ្សេងៗដែលអាចកើតឡើងពីពាក្យសំដី។

៤- ផលនៃការរួបរួមគ្នាតែមួយ:

បើការរួបរួមគ្នាក្នុងពេលអៀ្យកទីកាហ្វជាផលបុណ្យហើយនោះ ដូចនេះសូមអ្នកធ្វើការប្រលងប្រជែងគ្នាក្នុងការគោរពប្រតិបត្តិចំពោះអល់ឡោះនិងសុំការយល់ព្រមពីទ្រង់ផងដែរ ។ បើអ្នកអៀ្យកទីកាហ្វពីរថ្ងៃឬបីថ្ងៃ អ្នកត្រូវដឹងថានៅទីនេះក៏មានអ្នកអៀ្យកទីកាហ្វចំនួន១០ថ្ងៃផងដែរ។ បើអ្នកបានបញ្ចប់ការសូត្រអាល់គួរអានម្តង អ្នកត្រូវដឹងថានៅទីនេះ ក៏មានអ្នកបញ្ចប់ការសូត្រអាល់គួរអានចំនួនពីរដងឬបីដងដែរ ។ បើអ្នកសឡាហ៏ពេលយប់មួយម៉ោង អ្នកត្រូវដឹងថានៅទីនេះមានអ្នកសឡាហ៏មួយភាគបីនៃយប់ ឬពាក់កណ្តាលយប់ដូច្នេះដើម្បីអោយអារម្មណ៏របស់អ្នកក្នុងនាមជាអ្នកអៀ្យកទីកាហ្វ និងនៅលាយលំជាមួយអ្នកដទៃដែរ នោះបើអ្នកមានលទ្ធភាពទប់ស្កាត់មិនអោយនរណាម្នាក់យកឈ្នះលើរូបអ្នកក្នុងកិច្ចប្រតិបត្តិសាសនារបស់អល់ឡោះ ចូរអ្នកធ្វើវាភ្លាម !!!

## នាទីចុងក្រោយ......មិនអាចបដិសេធបាន

លោកអ៊ិបនូអាល់មុនហ្សេរកូនអ៊ូហ៊្វែដបាននិយាយថាៈ (លោកអ៊ូមើរកូនអាប់ឌុលអាហ្ស៊ីសឡើងគ្រប់គ្រងប្រទេសក្រោយពីសឡាហ៏ជុំអាត់ លុះដល់ពេលសឡាហ៏អាសើរ ប្រជាជនបាននាំគ្នាបដិសេធសមាសភាពរបស់លោក)។ មនុស្សម្នាបានបដិសេធសមាសភាពអ៊ូមើរក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយការឡើងកាន់តំណែងជាថ្នាក់ដឹកនាំប្រទេស ចុះចំពោះរូបអ្នកដែលជាអ្នកអៀ្យកទីកាហ្វវិញយ៉ាងណាដែរ ក្រោយពីចំណាយរយៈពេល១០ថ្ងៃនោះ!



- តើអ្នកទៅជួបមនុស្សវិញក្នុងទឹកមុខផ្សេងពីពេលមុនឬ?
- តើអ្នកមានកែលំអអត្តចរិករបស់ខ្លួនទេ ?
- តើអ្នកមានបង្កើនជំនឿដែរឬទេ?
- តើអ្នកមានបង្កើនសេចក្តីក្លាហានដែរឬទេ?
- តើអ្នកមានបង្កើនអារម្មណ៏រីករាយដែរឬទេ?

- តើវាសក្តិសមសំរាប់រូបអ្នកទេ បើអ្នកជ្រះស្អាតហើយរួចធ្វើអោយប្រឡាក់វិញនោះ!

- តើវាសក្តិសមសំរាប់រូបអ្នកទេ បើក្រោយពីបានដឹងខ្លឹមសារអាល់គួរអានហើយ បែរជាទៅគិតរឿងស្រីញីទៅវិញ!

- តើវាសក្តិសមសំរាប់រូបអ្នកទេ បើក្រោយពីក្រោកពីដំណេកក្នុងពេលទទួលទានបាយបួស ហើយបែរទៅជាដេកបង្ហួសសឡាហ៏ស៊ូហ្ពុះនោះ!

- តើវាសក្តិសមសំរាប់រូបអ្នកទេ ក្រោយពេលដែលអ្នកបានបោះជំហានដើម្បីអល់ឡោះនៅពេលយប់ ហើយបែរទៅជាពេលថ្ងៃបោះជំហានដើរទៅប្រព្រឹត្តអំពើហាមឃាត់ទៅវិញ ។

<u>ពោះមួយជាទីស្រលាញ់!</u>

- អ្នកត្រូវតែជំនះចិត្តអោយបាន ដើម្បីទទួលឋានសួគ៏ដ៏ខ្ពង់ខ្ពស់ពីអល់ឡោះម្ចាស់។
- សូមទប់អារម្មណ៏ពីការភ្លើតភ្លើនអោយអស់ពីលទ្ធភាព ។
- សូមពិនិត្យឡើងវិញនូវការសន្យារបស់អ្នកជាមួយអល់ឡោះម្ចាស់។

- ឥឡូវនេះអ្នកមិនត្រូវពន្យាពេលពីការប្រើប្រាស់ភាពវៃឆ្លាតក្នុងកិច្ចណាណាមួយនោះឡើយ ។

- គេដំដែកនៅពេលវាក្តៅ ។

- សូមអោយកំដៅនៃគោលជំនឿស្ថិតក្នុងដួងចិត្តរបស់អ្នកជានិច្ច ។

- សូមអោយអាល់គួរអានដែលគេគោរពប្រតិបត្តិតាមស្ថិតនៅលើអណ្តាតរបស់អ្នកជារៀងរហូត ។

- សូមអោយដំណក់ទឹកភ្នែកនៃការកោតខ្លាចអល់ឡោះស្ថិតនៅលើថ្ពាល់របស់អ្នកជាដរាប ។

- សូមអោយសេចក្តីសុខនៃខែរ៉ម៉ាដនស្ថិតក្នុងរាងកាយរបស់អ្នកតរៀងទៅ ។

ឥឡូវនេះ ចូរប្រញាប់ប្រញាល់ចាប់យកការប្រែប្រួលនៃជំនឿដោយការដកចេញអោយអស់នូវរាល់កំហុសឆ្គងរបស់អ្នក!!!

ពោះមួយជាទីស្រលាញ់!

- អ្នកកុំក្រអឺតក្រទមអោយសោះ ព្រោះអ្នកត្រូវអល់ឡោះជាអ្នកបញ្ចូលព្រលឹងអោយ ។

- អ្នកមិនត្រូវយកការព្យាយាមរបស់អ្នកដើម្បីមើលងាយមើលថោកដល់អ្នកដទៃឡើយ ព្រោះអល់ឡោះនឹងផ្តល់ផលដល់អ្នកតាមទង្វើតូចធំរបស់អ្នក ។

- អ្នកមិនត្រូវយល់អាក្រក់ទៅលើអល់ឡោះម្ចាស់ឡើយ ព្រោះទ្រង់ជាអ្នកថ្កុំថ្កើងលើសអ្វីៗទាំងអស់ ។ បើទ្រង់មិនស្រលាញ់រូបអ្នកទេ ទ្រង់នឹងមិនជ្រើសរូបអ្នកក្នុងចំណោមអ្នកដទៃដើម្បីអៀកទីកាហ្វឡើយ ហើយទ្រង់ក៏មិនផ្តល់រសជាតិនៃជោគជ័យនិងរសជាតិនៃការសូត្រធម៌នឹកគិតចំពោះអល់ឡោះម្ចាស់ដែរ និងទ្រង់ក៏មិនបង្អាក់អ្នកសំរាប់ការបំរើទ្រង់នោះឡើយ ហើយទ្រង់ក៏មិនប្រទានពរជ័យដល់អ្នកដែរ ។

អ្នកមិនត្រូវសងគុណអល់ឡោះដោយការប្រព្រឹត្តអំពើអបាយមុខចំពោះទ្រង់នោះឡើយ ហើយទ្រង់ជាអ្នកលើកតំកើងរូបអ្នកក្នុងពេលដែលអ្នកកំណាញ់ខ្លួនឯងនោះ ។

**ដូចនេះ សូមធ្វើខ្លួនជាខ្ញុំរបស់អល់ឡោះម្នាក់ដែលចេះសំដែងការអរគុណឌ**

# d v c

## យប់កឌើរ(យប់ដ៏ថ្កុំថ្កើង)

អល់ឡោះបានបន្ទំនិងលើកតំកើងយប់កឌើរនេះ ដើម្បីបញ្ចុះអាល់គួរអាននៅយប់នោះអល់ឡោះបានមានបន្ទូលថាៈ (យើងបានបញ្ចុះអាល់គួរអាននៅយប់កឌើរ តើអ្នកដឹងទេអ្វីទៅជាយប់កឌើរនោះ? យប់កឌើរល្អជាងមួយពាន់ខែ! បណ្តាពពួកម៉ាឡើអ៊ីកះនិងម៉ាឡើអ៊ីកះជីបរ៉អ៊ីលបានចុះនៅយប់នោះ ដោយការអនុញ្ញាតពីម្ចាស់របស់ពួកគេ សំរាប់កិច្ចការទាំងឡាយ(ក្នុងឆ្នាំនោះ) មានសេចក្តីសុខក្សេមក្សាន្តរហូតដល់ពេលស៊ូប៉្ហះ) ។ (ជំពូកអាល់កត់រី)

ការបួងសួងសុំនៅក្នុងយប់នោះគឺជាការចង្អុលបង្ហាញពីណាហ្ពីមូហាំម៉ាត់ ។ អ្នកស្រីអាអ៊ីសះបាននិយាយថាៈ រ៉ស៊ូលុលឡោះបានមានប្រសាសន៏ថាៈ (បើខ្ញុំបានដឹងពីយប់កឌើរ ខ្ញុំនឹងបួងសួងសុំថាៈ(ឱអល់ឡោះម្ចាស់! ទ្រង់ជា

អ្នកប្រណីទោស ពេញចិត្តការសណ្តោសប្រណី សូមទ្រង់សណ្តោសប្រណីដល់ពួកយើងខ្ញុំផងចុះ ។

## បរិច្ចាគទានហ្សាកាត់ហ្វិតត្រោះ

អ្នកមូស្លីមគ្រប់រូបត្រូវបរិច្ចាគហ្សាកាត់នេះដល់អ្នកខ្វះខាតដើម្បីជំរះសំអាតខ្លួនគេ និងជំរះសំអាតពីអ្វីដែលបានកើតឡើងក្នុងពេលបួស ពីពាក្យសំដីនិងទង្វើមិនសមរម្យផ្សេងៗ ។

លោកអាប់ឌុលឡោះកូនលោកអាប់ហ្គើសបាននិយាយថាៈ ”រ៉ស៊ូលុលឡោះបានដាក់កាតព្វកិច្ចហ្សាកាត់ហ្វិតត្រោះដើម្បីជំរះសំអាតអ្នកបួសពីទង្វើឆ្គាំឆ្គង និងពាក្យសំដីដែលមិនសមរម្យ ហើយវាអាចផ្តល់ជាចំណីអាហារដល់ទុរគតជនផងដែរ ។ (រាយការណ៍ដោយអ៊ីម៉ាំអាហ្ពូឌើវូត)

<u>ពេលវេលាសំរាប់ការបរិច្ចាគទានហ្សាកាត់ហ្វិតត្រោះ :</u>

ហ្សាកាត់នេះអាចបរិច្ចាគចាប់ពីដើមខែបួសរ៉ម៉ាដនមកបាន ហើយជាការប្រសើរបំផុតគឺបរិច្ចាគនៅព្រឹកថ្ងៃរ៉យ៉ើមុនសឡាហ៍ តែមិនអាចពន្យាពេលរហូតផុតសឡាហ៏ដោយគ្មានធុរៈនោះឡើយ ។

<u>ហ្សាកាត់ហ្វិតត្រោះត្រូវចេញអោយនរណាខ្លះ :</u>

បុគ្គលម្នាក់ត្រូវចេញសំរាប់ខ្លួនឯង និងចេញអោយអ្នកដែលខ្លួនត្រូវចិញ្ចឹមបីបាច់ថែរក្សាប្រចាំថ្ងៃ ដូចជាប្រពន្ធកូន និងសាច់ញាត ។

<u>សមាសភាពដែលអាចទទួលហ្សាកាត់ហ្វិតត្រោះ :</u>



ហ្សាកាត់នេះត្រូវផ្តល់ទៅអោយអ្នកក្រីក្រដែលមានតំរូវការ ដែលពួកគេគ្មានចំណូលអាចបំពេញសេចក្តីត្រូវការរបស់គេបាន ក្នុងនោះក៏រាប់អ្នកធ្វើដំណើរនិងអ្នកបំលាស់ទីផងដែរ ។

<u>បរិមាណដែលត្រូវចេញហ្សាកាត់ហ្វិតត្រោះ :</u>

បុគ្គលម្នាក់ៗត្រូវចេញចំនួនមួយកន្តាំងរបស់រ៉ស៊ូលុលឡោះដែលមានទំងន់ស្មើនឹង២.៤គីឡូក្រាម ពីចំណីសំរាប់ចំអែតប្រចាំថ្ងៃនៅក្នុងតំបន់នោះ ។

**d w c**

### ការសូត្រតឹកប្ពៀរនៅថ្ងៃរ៉យ៉ើទាំងពីរ :

اَللهُ أَكْبَرُ- اَللهُ أَكْبَرُ - اَللهُ أَكْبَرُ - لاَ إِلَهَ إِلاَّ اللهُ وَاللهُ أَكْبَرُ - اَللهُ أَكْبَرُ وَلِلَّهِ الْحَمْدُ .

اَللهُ أَكْبَرُ كَبِيْرًا وَالْحَمْدُ لِلَّهِ كَثِيْرًا وَسُبْحَانَ اللهِ بُكْرَةً وَأَصِيْلاً لاَ إِلَهَ إِلاَّ اللهُ وَلاَ نَعْبُدُ إِلاَّ إِيَّاهُ مُخْلِصِيْنَ لَهُ الدِّيْنَ وَلَوْكَرِهَ الْكَافِرُوْنَ . لاَ إِلَهَ إِلاَّ اللهُ وَحْدَهُ صَدَقَ وَعْدَهُ وَنَصَرَ عَبْدَهُ وَأَعَزَّ جُنْدَهُ وَهَزَمَ الْأَحْزَابَ وَحْدَهُ - لاَ إِلَهَ إِلاَّ اللهُ وَاللهُ أَكْبَرُ - اَللهُ أَكْبَرُ وَلِلَّهِ الْحَمْدُ .

**d x c**